អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា/កូរ៉េខាងត្បូងកើនជាង៣១%ក្នុងខែមករា ឆ្នាំ២០២២
- កម្ពុជា កំពុងបន្តស្វែងរកក្រុមហ៊ុនវិនិយោគថ្មីពីក្រៅប្រទេស ដើម្បីបន្តអភិវឌ្ឍវិស័យប្រេងកម្ពុជា
- បើសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនអូសបន្លាយ នឹងអាចប៉ះពាល់ដល់ការនាំចេញពីកម្ពុជាទៅអឺរ៉ុប
- តើអាស៊ាន អាចនឹងរងឥទ្ធិពលយ៉ាងណាខ្លះពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ?
- ធនាគារជាតិថៃ ព្រមានអំពីអតិផរណាខ្ពស់ជាងមុន
- ទិន្នផលរោងចក្ររបស់ជប៉ុន រងការធ្លាក់ចុះដោយសារការកាត់បន្ថយផលិតកម្មរបស់ក្រុមហ៊ុនផលិតរថយន្ត ខណៈវិបត្តិនៅប្រទេសអ៊ុយក្រែនបន្ថែមហានិភ័យ
- កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី១ ពិភាក្សាលើរបៀបវារៈជំរុញកំណើនសេដ្ឋកិច្ចនៅអាស៊ាន
- អតិផរណាគ្រឿងទេសនៅចក្រភពអង់គ្លេសឡើងដល់៤,៣% ខណៈជម្លោះនៅអ៊ុយក្រែនបន្ថែមសម្ពាធ
- ឱនភាពពាណិជ្ជកម្មទំនិញរបស់សហរដ្ឋអាមេរិកបានឡើងដល់កម្រិតខ្ពស់បំផុត ដែលមើលឃើញថាមានទម្ងន់លើកំណើន GDP នៅត្រីមាសទីមួយ
- សហរដ្ឋអាមេរិក កាត់ផ្តាច់ធនាគារកណ្តាលរុស្ស៊ី ចេញពីការជួញដូរប្រាក់ដុល្លារអាមេរិក
- ធនាគារកណ្តាល៖ រុស្ស៊ីមានប្រព័ន្ធផ្ទៃក្នុងដែលអាចជំនួស SWIFT បាន

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជាបានមើលឃើញពីភាពសុទិដ្ឋិនិយមការងារតាមរយៈការកើនឡើងនៃការផ្ញើរប្រាក់



*ប្រភព៖ភ្នំពេញប៉ុស្តិ៍, ២០២២ រូបភាព៖ ហុង មិនា*

យោងតាមតួលេខថ្មីរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញថាការផ្ញើប្រាក់សរុបពីពលករចំណាកស្រុកកម្ពុជាបានកើនឡើងកាលពីឆ្នាំមុន បើទោះបីជាវិបត្តិសេដ្ឋកិច្ចនៅតែបន្តកើតមានដោយជំងឺកូវីដ-១៩ ក៏ដោយ ខណៈដែលប្រាក់ឈ្នួល និងការផ្ញើរប្រាក់ក្នុងស្រុកសរុបមានចំនួន ៦,៧ ប៊ីលានដុល្លារ។

នៅក្នុងឆ្នាំ២០២១មាន កម្មករធ្វើការតាមផ្ទះចំនួន ១,៤លាននាក់ ,នៅសហគ្រាសចំនួន ១៣ ៥៧១នាក់ ដែលបានចុះបញ្ជីក្នុងប្រទេសកម្ពុជា នឹងទទួលបានប្រាក់ឈ្នួលសរុបចំនួន ៣,៧ប៊ីលានដុល្លារ ខណៈដែល ពលករចំណាកស្រុកកម្ពុជាមានចំនួន ១,៣ លាននាក់នឹងបានបញ្ជូនប្រាក់សរុបចំនួន ៣ ប៊ីលានដុល្លារត្រឡប់មកកម្ពុជាវិញកើនពី ១,២ ប៊ីលានដុល្លារក្នុងឆ្នាំ ២០២០។

ការកើនឡើងនៃការផ្ញើប្រាក់ដែលផ្ញើឡើងដោយពលករទៅក្រៅប្រទេសអាចបណ្តាលមកពីការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុបន្ថែមដែលផ្តល់ដោយនិយោជក។ ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ សហគ្រាសនៅក្នុងប្រទេសដូចជាកូរ៉េខាងត្បូង និងថៃ ដែលជាកន្លែងមានប្រជាជនកម្ពុជាជាច្រើនធ្វើការនៅក្នុងរោងចក្រផលិតកំប៉ុង ឬវេចខ្ចប់អាហារ បានរក្សាសង្វាក់ផលិតកម្មរបស់ពួកគេ ដែលជួនកាលផ្តល់ប្រាក់បន្ថែមម៉ោង និងប្រាក់រង្វាន់ដែល កត្តា នេះនាំឱ្យប្រាក់ឈ្នួលត្រូវបានដំឡើង។ ការបន្តរីកចម្រើននៃវិស័យផលិតកម្ម ដែលរួមមានឧស្សាហកម្មកាត់ដេរ បានជះឥទ្ធិពលជាវិជ្ជមានទៅលើវិស័យផ្សេងទៀត ដូចជាសំណង់ និងទេសចរណ៍ ដែលផ្នែកចុងក្រោយនេះប្រឈមនឹងការធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការបិទព្រំដែនក្នុងអំឡុងពេលមានការរាតត្បាតសកល។

ការងារ និងប្រាក់ចំណូលរបស់ពលករកម្ពុជានៅក្រៅប្រទេសនិងក្នុងស្រុកបានជំរុញសេដ្ឋកិច្ច និងសង្គមតាមរយៈការជួយផ្គត់ផ្គង់គ្រួសាររបស់ពួកគេដែលបន្តរស់នៅក្នុងប្រទេសកម្ពុជា។ ទោះបីជាមានការថយចុះបើធៀបនឹងរយៈពេលមុនជំងឺរាតត្បាតក៏ដោយ ប្រាក់ឈ្នួលរហូតមកដល់ពេលនេះបានបង្ហាញថាសកម្មភាពផលិតកម្មបានបន្តមានស្ថិរភាព និងបង្ហាញពីការកើនឡើងនៃតម្រូវការការងារ ដូច្នេះអត្រាប្រាក់ចំណូលរបស់ បុគ្គលិកកម្ពុជាទាំងក្នុងស្រុក និងក្រៅស្រុកនឹងបន្តកើនឡើង។

របាយការណ៍របស់ក្រសួងការងារបង្ហាញថា មានពលករខ្មែរនៅក្រៅប្រទេសមានចំនួន ១ ៣០១ ៦០៩ នាក់ ក្នុងនោះពលករធ្វើការងារនៅប្រទេសថៃមានចំនួនច្រើនជាងគេចំនួនគឺ ១ ២២០ ១៩៧នាក់។ កូរ៉េខាងត្បូងបានជាប់លេខ២គឺ ៤៥ ៨៦៦។ ប្រទេស និងដែនដី

ផ្សេងទៀតដែលមានចំនួនពលករចំណាកស្រុកកម្ពុជាច្រើនរួមមាន ម៉ាឡេស៊ី មាន ២៣ ០២៧ នាក់, ជប៉ុន ១១ ៩៥៣ នាក់ ,សិង្ហបុរី ៨២១ នាក់ ហុងកុង ២០២ នាក់ និង អារ៉ាប៊ីសាអូឌីត ៤៣ នាក់៕*ដោយ សេន ចន្ទី*

*ប្រភព៖phnompenhpost,ចេញផ្សាយថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០២២*

## ការធ្វើពាណិជ្ជកម្មទ្វេភាគីកម្ពុជា និងកូរ៉េខាងត្បូងកើនឡើងជាង៣១%ក្នុងខែមករា ឆ្នាំ២០២២




*ប្រភព៖ភ្នំពេញប៉ុស្តិ៍, ២០២២ រូបភាព៖ ហេង ជីវ័ន្ត*

យោងតាមទិន្នន័យពីសមាគមពាណិជ្ជកម្មអន្តរជាតិកូរ៉េ (KITA) បានបញ្ជាក់ថា ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងកូរ៉េខាងត្បូងឈានដល់ ១១១,៣ លានដុល្លារក្នុងខែដំបូងនៃឆ្នាំ ២០២២ កើនឡើងជាង ៣១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១មានចំនួន៨៤,៩ លានដុល្លារ។

ក្នុងខែមករា ឆ្នាំ២០២២ ការនាំចេញរបស់កម្ពុជាទៅកាន់កូរ៉េខាងត្បូងមានចំនួន ៣៣ លានដុល្លារ កើនឡើងជិត១%ធៀបនឹងឆ្នាំមុនមាន៣២,៦លានដុល្លារ។ ទន្ទឹមនឹងនេះដែរ ការនាំចូលបានកើនឡើងដល់ ៧៨ លានដុល្លារ កើនឡើង ៤៩,៨%ធៀបនឹងឆ្នាំមុន៥២,២ លានដុល្លារ។

ឱនភាពពាណិជ្ជកម្មរបស់កម្ពុជាជាមួយកូរ៉េខាងត្បូងមានចំនួនជាង ៤៥ លានដុល្លារក្នុងខែមករា កើនឡើងជាង ១៣១%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន នឹងកើនឡើង ៤៧%ធៀបនឹងខែធ្នូឆ្នាំ២០២១។ ជាទូទៅ ការនាំចេញសំខាន់ៗរបស់កម្ពុជាទៅកាន់កូរ៉េខាងត្បូងរួមមាន សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ គេសជ្ជៈ គ្រឿងបន្លាស់ អេឡិចត្រូនិច កៅស៊ូ ឱសថ និង ផលិតផលកសិកម្ម ខណៈដែលការនាំចូលសំខាន់ៗរួមមាន រថយន្ត គ្រឿងអេឡិចត្រូនិច ឧបករណ៍ផ្ទះបាយ គេសជ្ជៈ ឱសថ និងប្លាស្ទិក ដែលទំនិញខ្លះគឺប្រើប្រាស់ក្នុងការផលិតទំនិញសម្រាប់នាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

ស្របពេលជាមួយគ្នានេះដែរ,មន្ត្រីជំនាញជាន់ខ្ពស់របស់ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ផងដែរថា៖ទោះបីជាការនាំចេញរបស់ កម្ពុជាទៅកាន់កូរ៉េខាងត្បូងក្នុងខែមករាមានតិចជាងពាក់កណ្ដាលនៃតម្លៃនៃការនាំចូល ឬ ៤២%ក៏ដោយតែក៏ជានិន្នាការកើនឡើងនៃពាណិជ្ជកម្មទ្វេភាគីដែល បង្ហាញពីជំហររឹងមាំរបស់ប្រទេសទាំងពីរជាដៃគូពាណិជ្ជកម្មបើទោះបីជាមានវិបត្តិកូវីដ-១៩ក្ដី។ សូមបញ្ជាក់ផងដែរ, នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២១ ភាគីទាំងពីរប្រទេសបានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលនឹងអាចផ្ដល់នូវការចូលប្រើប្រាស់ ទំនិញកម្ពុជាជាង ១០ ០០០ មុខដោយមិនគិតពន្ធទៅកាន់ទីផ្សារកូរ៉េខាងត្បូង។ នៅក្រោមកិច្ចព្រមព្រៀងនេះ រួមជាមួយនឹងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) កម្ពុជានឹងដកពន្ធលើទំនិញចំនួន ៩៣,៨ %នៃទំនិញដែលត្រូវបានជួញដូរដោយកូរ៉េខាងត្បូងបានលុបចោលពន្ធលើ ៩៥,៦%។

កិច្ចព្រមព្រៀងនេះនឹងជួយពន្លឿនលំហូរពាណិជ្ជកម្មក្នុងទំនិញរវាងប្រទេសទាំងពីរប៉ុន្តែសមតុល្យពាណិជ្ជកម្មអាចមានភាពលំអៀងនៅក្នុងការពេញចិត្តរបស់កម្ពុជាប្រសិនបើកម្ពុជាកែសម្រួលសមត្ថភាពផលិតកម្មរបស់ខ្លួនឱ្យកាន់តែសមស្របទៅនឹងតម្រូវការទីផ្សារកូរ៉េ។

យោងតាមទិន្នន័យពីធនាគារជាតិនៃកម្ពុជា ,គិតត្រឹមឆមាសទី១នៃឆ្នាំ២០២១ ប្រទេសកម្ពុជាបានទាក់ទាញ

ការវិនិយោគផ្ទាល់ពីបរទេស (FDI) ចូលថ្មីសរុបចំនួន ៣៩ប៊ីលានដុល្លារ ដោយប្រទេសកូរ៉េខាងត្បូងជាប់ចំណាត់ថ្នាក់ជាប្រភពធំទីពីរនៃ FDI ដែលបានចុះបញ្ជីជាមួយនឹងភាគហ៊ុន ១០,៦% ឬ ៤,១ប៊ីលានដុល្លារ នៅពីក្រោយប្រទេសចិនដែលមានចំនួន១៧,៣ប៊ីលានដុល្លារ។ *ដោយ សេន ចន្ទី*

*ប្រភព៖phnompenhpost,ចេញផ្សាយថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០២២*

## កម្ពុជា កំពុងបន្តស្វែងរកក្រុមហ៊ុនវិនិយោគថ្មីពីក្រៅប្រទេស ដើម្បីបន្តអភិវឌ្ឍវិស័យប្រេងកម្ពុជា



*ដោយ ខេមបូណ្ណមីស*

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា កំពុងស្វែងរកការវិនិយោគពីក្រៅប្រទេស សម្រាប់ការអភិវឌ្ឍវិស័យប្រេងរបស់កម្ពុជា នៅក្រោយពេលដែលក្រុមហ៊ុនរុករកប្រេង KrisEnergy បានផ្អាកប្រតិបត្តិការបូមប្រេងរបស់ខ្លួននៅកម្ពុជា។ ឯកអគ្គរដ្ឋទូតអ៊ីស្លាមអ៊ីរ៉ង់ បានបង្ហាញជំហរ ចង់ចូលរួមអភិវឌ្ឍន៍វិស័យបូមប្រេងនៅកម្ពុជា ដែលកំពុងជាប់គាំង។ ហើយក៏បានបង្ហាញការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការកៀរគរវិនិយោគិនអ៊ីរ៉ង់ឱ្យមកវិនិយោគលើវិស័យប្រេងកាត និងថាមពលនៅកម្ពុជា។

ក្រៅពីប្រទេសអ៊ីរ៉ង់ កម្ពុជាក៏កំពុងទាក់ទងជាមួយបណ្ដាប្រទេសមួយចំនួនទៀតមកអភិវឌ្ឍន៍លើវិស័យប្រេងកាតនៅកម្ពុជា។

គិតមកទល់ពេលនេះមានរយៈពេលប្រមាណជាង៨ខែហើយ ដែលការបូមប្រេងពីប្លុក A នៅតំបន់អប្សរាក្នុងឈូងសមុទ្រកម្ពុជា បានផ្អាកប្រតិបត្តិការ បន្ទាប់ពីក្រុមហ៊ុនរុករក និងបូមប្រេង KrisEnergy ស្នើសុំតុលាការសិង្ហបុរីប្រកាសក្ស័យធន និងសុំលក់ទ្រព្យសម្បត្តិ ដើម្បីសងម្ចាស់បំណុល។ ការប្រកាសក្ស័យធនរបស់ក្រុមហ៊ុនបូមប្រេងមួយនេះ គឺធ្វើឡើងបន្ទាប់ពីក្រុមហ៊ុននេះគ្មានលទ្ធភាពសងបំណុលជូនដល់ម្ចាស់បំណុល ក្រោយខ្លួនអស់ជម្រើសក្នុងការកៀរគរទុន និងបំណុលកើនលើសតម្លៃទ្រព្យសកម្ម។ ការបូមប្រេងពីអណ្ដូងនៅកម្ពុជា ទទួលបានទិន្នផលតិចជាងការរំពឹងទុក ក៏ជាមូលហេតុមួយ ដែលធ្វើឱ្យក្រុមហ៊ុននេះ ប្រឈមនឹងបន្ទុកបំណុលវ័ណ្ឌកផងដែរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ណមីស ចេញផ្សាយថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។*

## អាជ្ញាធរកម្ពុជា ប្ដេជ្ញាថា នឹងហាមឃាត់ការធ្វើអាជីវកម្មបារី អេឡិចត្រូនិក ខណៈគេបាម្ភពីជំងឺឆ្លង




*ដោយ Campost*

រាជរដ្ឋាភិបាលបានហាមឃាត់ការប្រើប្រាស់ ការនាំចូល និងការធ្វើអាជីវកម្មបារីអេឡិចត្រូនិក និងផលិតផល អេចធ៍ ធី ភី (HTPs) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ខណៈឧបករណ៍នេះបានបង្កហានិភ័យដល់សុខភាពអ្នកប្រើប្រាស់ ដើម្បីកុំឱ្យបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរនិងការចម្លងជំងឺពីម្នាក់ទៅម្នាក់ដោយសារ ការប្រើប្រាស់រួមគ្នាជាពិសេសជំងឺកូវីដ-១៩។

អាជ្ញាធរមានសមត្ថកិច្ចទូទាំង២៥រាជធានី-ខេត្ត គាំទ្រ និងប្ដេជ្ញាពង្រឹងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធបង្កើន

ការផ្សព្វផ្សាយ និងទប់ស្កាត់ការប្រើប្រាស់ផលិតផលនេះឱ្យមានប្រសិទ្ធភាព។

ប្រធាននាយកដ្ឋាននីតិកម្ម អប់រំ និងស្ដានីតិសម្បទា នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានមានប្រសាសន៍ថា អ្នកពាក់ព័ន្ធមកពីទូទាំងប្រទេស បានគិតគូរយ៉ាងខ្លាំងលើបញ្ហានេះ ដោយបានពិភាក្សារកវិធីសាស្រ្តថ្មីៗក្នុងការអនុវត្តន៍សេចក្ដីណែនាំរបស់រាជរដ្ឋាភិបាល លេខ ០០១/១៤ ស.ណ.ជ.អ.ជ.ប.គ.ញ និងសេចក្ដីណែនាំលេខ ០០១/២១ ស.ណ.ជ.អ.ជ.ប.គ.ញ ដែលមានខ្លឹមសារហាមឃាត់ការប្រើប្រាស់ ការនាំចូល និងការធ្វើអាជីវកម្មបារីអេឡិចត្រូនិក និងផលិតផលអេចធ៍ ធី ភី (HTPs) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាពិសេស នឹងបង្កើនការផ្សព្វផ្សាយផលប៉ះពាល់ និងសម្របសម្រួលជំរុញពាក់ព័ន្ធទៅនឹងលិខិតបទដ្ឋានគតិយុត្តិ ច្បាប់ សម្រាប់ជាបង្អែកក្នុងការអនុវត្ត។កន្លងមកនេះ ទោះបីជារាជរដ្ឋាភិបាលបានចេញនូវសេចក្ដីណែនាំហាមឃាត់ការប្រើប្រាស់ ការនាំចូល និងការធ្វើអាជីវកម្មបារីអេឡិចត្រូនិក និងផលិតផលអេចធ៍ ធី ភី (HTPs) នៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០១៤ និងដើមឆ្នាំ២០២១ យ៉ាងណាក្ដី ក៏សកម្មភាពនៃការលក់ និងការប្រើប្រាស់នៅមិនទាន់បាត់លុបចេញពីប្រទេសកម្ពុជានៅឡើយទេ។ កម្ពុជានៅតែមានអ្នកប្រើប្រាស់ផលិតផលខុសច្បាប់នេះ ហើយពួកគេថែមទាំងហ៊ានបង្ហាញសកម្មភាពនៅលើបណ្ដាញទំនាក់ទំនងសង្គមទៀតផង។ ចំពោះអ្នកនាំចូល និងធ្វើអាជីវកម្មលើផលិតផលខុសច្បាប់ទាំងនេះវិញ គឺបានបញ្ចេញសកម្មភាពលក់យ៉ាងគឃ្លើនមិនថា Post ឬ Live លក់ នៅលើបណ្ដាញទំនាក់ទំនងសង្គម ដូចជា Tik Tok Instagram Telegram និងជាពិសេសគឺ Facebook។ ទាក់ទិននឹងការលក់ឃើញមានភាពលាក់បាំង។ អ្នកលក់ខ្លះលក់នៅទីតាំងក្រោមរូបភាពហាងកាហ្វេ ឬហាងផ្សេងទៀត ឯខ្លះទៀតមានលក្ខណៈជាការណាត់ទីតាំងដើម្បីដោះដូរទំនិញ។

នាយកប្រតិបត្តិ អង្គការចលនាដើម្បីសុខភាពកម្ពុជា បានឱ្យដឹងថា ការប្រើប្រាស់បារីអេឡិចត្រូនិក និងផលិតផលអេចធ៍ ធី ភី (HTPs) គឺមានគ្រោះថ្នាក់ខ្លាំងណាស់ ក្នុងនោះរួមមានការផ្ទុះដែលបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងការចម្លងជំងឺពីម្នាក់ទៅម្នាក់ដោយសារការប្រើប្រាស់រួមគ្នា។ លើសពីនេះសូលុយស្យុងស្ទិតដែលប្រើនៅក្នុងបារីអេឡិចត្រូនិក និងផលិតផលអេចធ៍ ធី ភី គឺមានផ្ទុកនូវសារធាតុគីមីគ្រោះថ្នាក់ជាច្រើនដូចជាសារធាតុគីមីផ្ដល់រសជាតិ នីកូទីន គ្លីសេរីន និងប្រូពីឡែន គ្លីកូលជាដើម។ នីកូទីនគឺធ្វើឱ្យញៀនខ្លាំង ចំពោះស្ត្រីមានផ្ទៃពោះគឺធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់គភ៌ និងបំផ្លាញការអភិវឌ្ឍសមត្ថភាពខួរក្បាល។ សម្រាប់យុវជន វានឹងធ្វើឱ្យប៉ះពាល់ដល់ការសិក្សា ការចងចាំ ការផ្ចង់អារម្មណ៍ និងជាផ្លូវមួយនាំពួកគេទៅរកការប្រើប្រាស់គ្រឿងញៀនគ្រោះថ្នាក់ផ្សេងទៀតនាពេលអនាគត។ ចំហាយដែលបានមកពីសូលុយស្យុងស្ទិតនេះគឺមានសមត្ថភាពនាំយកសារធាតុគីមីគ្រោះថ្នាក់បង្កជំងឺមហារីកចូលទៅក្នុងសួតបានកាន់តែជ្រៅ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ Campost ចេញផ្សាយថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ២០២២។*

## តម្លៃមាសនៅកម្ពុជាឡើង ដល់ជាង ២ ៣០០ដុល្លារក្នុង ១តម្លឹង ក្រោយផ្ទុះសង្គ្រាមនៅអ៊ុយក្រែន



*ដោយ ខេមបូណូមីស*

មាសនៅកម្ពុជា បានឡើងថ្លៃជាបន្តបន្ទាប់ ស្របទៅតាមនិន្នាការតម្លៃទីផ្សារពិភពលោក ក្នុងរយៈពេលប្រមាណ១សប្តាហ៍មកនេះ។ ក្រុមអាជីវករលក់មាសនៅកម្ពុជា បានអះអាងថា តាំងពីផ្ទុះសង្គ្រាមនៅអ៊ុយក្រែន មាសលក់ចេញនៅលើទីផ្សារកម្ពុជា បានឡើងថ្លៃប្រមាណ២០០ដុល្លារអាមេរិកបន្ថែមទៀតក្នុងមួយតម្លឹង។ លោកស្រី គង់ ពិសី ម្ចាស់ហាងមាសពេជ្រ ហេង ហេង នៅខាងត្បូងផ្សារថ្មីរាជធានីភ្នំពេញ ម្ចាស់ហាងមាសពេជ្រ ទីមង្គល និងម្ចាស់ហាងមាសពេជ្រនាគមាស បានប្រាប់ថា តម្លៃមាសនៅកម្ពុជា បានឡើងថ្លៃយ៉ាងគំហុក ឡើងរហូតដល់២ ៤០០ដុល្លារអាមេរិកក្នុង១តម្លឹង នៅមួយថ្ងៃបន្ទាប់ពីរុស្ស៊ីបានប្រកាសបើកការវាយប្រហារទៅលើប្រទេសអ៊ុយក្រែន។ ប៉ុន្តែ នៅថ្ងៃទី ០១ ខែមីនានេះ បានធ្លាក់មកនៅត្រឹម២ ៣០០ដុល្លារអាមេរិកវិញហើយក្នុង១តម្លឹង។ មុនពេលមានសង្គ្រាមនៅអ៊ុយក្រែន មាស១តម្លឹងលក់ចេញតែ១ ៨០០ដុល្លារអាមេរិកតែប៉ុណ្ណោះ។

បើទោះបីជា តម្លៃមាសឡើងថ្លៃក្តី ប៉ុន្តែ ក្រុមអាជីវករលក់មាសបានរអ៊ូទាំថា ចរន្តទិញលក់មាសធ្លាក់ចុះក្នុងរង្វង់៥០% នៅមួយរយៈចុងក្រោយនេះ បន្ទាប់ពីចំនួនអ្នកឆ្លងជំងឺកូវីដ-១៩ ប្រភេទអូមីក្រុងបានកើនឡើងដល់តួលេខបីខ្ទង់នៅប៉ុន្មានសប្តាហ៍មកនេះ៕

*ដោយ ម៉ែនខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២។*

## ឯកឧត្តម ឧកញ៉ា ម៉ុង ឫទ្ធី ៖ ទីផ្សារផ្លែស្វាយកែវរមៀតកំពុងធ្លាក់ថ្លៃខ្លាំង



ឯកឧត្តម ឧកញ៉ា ម៉ុង ឫទ្ធី បានលើកឡើងទាក់ទងនឹងផ្លែស្វាយកែវរមៀតគ្មានទីផ្សារ និងមានការធ្លាក់ថ្លៃមិនធ្លាប់មានពីមុនមក។ សម្រាប់ស្វាយកែវរមៀតខ្ចប់វិញគ្មានទីផ្សារតែម្តង ដោយសារតែគ្មានមធ្យោបាយសម្រាប់នាំចេញ។ កន្លងមក ផ្លែស្វាយរបស់ឯកឧត្តមត្រូវដឹកតាមយន្តហោះនាំចេញទៅកាន់ទីផ្សារ។ ជាក់ស្តែង ផ្លែស្វាយកែវរមៀតក្រៅកញ្ចប់ គ្មានអ្នកមកទិញក្រៅពីឈ្មួញវៀតណាមនោះទេ ហើយលក់បានត្រឹមតម្លៃតែ ៤០០រៀលប៉ុណ្ណោះក្នុងមួយគីឡូក្រាម ដែលកន្លងមក លក់បានតម្លៃជាមធ្យម ៨០០រៀល ទៅ១ ២០០រៀលក្នុងមួយគីឡូក្រាម។ ដោយសារតែផ្លែស្វាយខ្ចប់គ្មានទីផ្សារ ឯកឧត្តម ត្រូវបង្ខំចិត្តលក់ផ្លែស្វាយក្រៅកញ្ចប់មួយចំនួនឱ្យទៅឈ្មួញវៀតណាម ក្នុងតម្លៃទាប។ ហើយផ្លែស្វាយមួយចំនួនទៀត ក៏ត្រូវប្រឈមនឹងការខូចខាត ផងដែរ។ ផ្លែស្វាយជួបបញ្ហាខ្វះទីផ្សារ គួបផ្សំថ្លៃជី ថ្នាំកសិកម្ម និងប្រេងឥន្ធនៈជាដើម សុទ្ធតែឡើងថ្លៃ បានធ្វើឱ្យក្រុមកសិករជួបផលលំបាកថែមទៀត។ ឯកឧត្តម ក៏អំពាវនាវដល់ក្រុមកសិករប្រកបរបរដាំដំណាំស្វាយ គួរងាកមកផលិតជីសរីរាង្គដោយខ្លួនឯងវិញ ព្រោះអាចកាត់បន្ថយថ្លៃដើមបានមួយកម្រិត។ កូវីដ១៩នៅតែឧបសគ្គធំក្នុងការនាំចេញ ហើយរហូតមកដល់ពេលនេះ នៅតាមព្រំដែនវៀតណាម-ចិន នៅតែ

បន្តមានការកកស្ទះកុងតឺន័រ ដូច្នេះទើបជះឥទ្ធិពលអវិជ្ជមានដល់ការនាំចេញផ្លែស្វាយកម្ពុជា។

ប្រធានសហគមន៍កសិកម្មសាមគ្គីតំបែរ បានឱ្យដឹងថា ផ្លែស្វាយកែវរមៀតចាប់ផ្តើមធ្លាក់ថ្លៃរហូត ៤០០ រៀល ទៅ៥០០រៀល ក្នុងមួយគីឡូក្រាម នឹងអាចបន្តធ្លាក់ថ្លៃជាងនេះក៏ថាបាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ហាក់មិនទាន់មានការឆ្លើយតបនៅឡើយ ជុំវិញបញ្ហាទីផ្សារផ្លែស្វាយនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២។*

## តំបន់នៃខេត្តក្វាងស៊ីប្រទេសចិនអនុញ្ញាតឱ្យកម្ពុជានាំចេញដំឡូងមីស្ងួត៤០ម៉ឺនតោន



*ដោយ ខេមបូណូមីស*

ដំឡូងមីក្រៀមរបស់កម្ពុជានៅឆ្នាំនេះ កំពុងមានទីផ្សារកាន់តែល្អប្រសើរ។ តួយ៉ាងថ្មីៗនេះ ក្រសួងពាណិជ្ជកម្មកម្ពុជា ទើបតែបានសម្របសម្រួលជាមួយខាងភាគីចិនបើកច្រកទីផ្សារនាំចេញដំឡូងស្ងួតពីកម្ពុជាចំនួន៤០ ម៉ឺនតោន ទៅកាន់តំបន់ស្វយ័តជនជាតិជាំងក្វាងស៊ីប្រទេសចិនចាប់ពី ឆ្នាំ២០២២-២០២៣។ ក្រុមកសិករនិងអាជីវកម្មទិញលក់ដំឡូងមី សង្ឃឹមថា តម្លៃទីផ្សារដំឡូងមី អាចនឹងកាន់តែល្អប្រសើរជាងមុន នៅពេលមានការបើកទីផ្សារនាំចេញកាន់តែច្រើន។ ក្រសួងពាណិជ្ជកម្មកម្ពុជា បានសហការរៀបចំពិធីចុះហត្ថលេខាស្តីពី កិច្ចសហប្រតិបត្តិការជំរុញពាណិជ្ជកម្ម រវាងអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មនៃតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ីនៃសាធារណរដ្ឋប្រជាមានិតចិន តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ។

អាជីវករទិញលក់ដំឡូងមី នៅខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា ទីផ្សារដំឡូងមីក្នុងឆ្នាំនេះល្អប្រសើរច្រើន បើធៀបទៅឆ្នាំ២០២១ ព្រោះតម្រូវការមានច្រើន តែទិន្នផលដំឡូងមីឆ្នាំនេះមានតិច ដោយសារតែមានភ្លៀងធ្លាក់ច្រើន។ កន្លងមកលោកបាននាំចេញទៅថៃ មិនបាននាំចេញផ្ទាល់ទៅកាន់ប្រទេសចិនទេ។ ការនាំចេញផ្ទាល់ទៅក្រៅប្រទេសបាន នោះតម្លៃក៏អាចលក់បានខ្ពស់ផងដែរ។

ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង បានគូសបញ្ជាក់ដែរថា តម្លៃទីផ្សារដំឡូងមីក្នុងឆ្នាំនេះ មានការកើនឡើងជាងឆ្នាំមុន ដោយតម្លៃជាមធ្យមដំឡូងមីស្រស់មានតម្លៃ ២៤០ រៀលមួយគីឡូក្រាម និងដំឡូងមីក្រៀម តម្លៃ ជាង៧២០ រៀលក្នុងមួយគីឡូក្រាម។ គោលដៅនាំចេញដំឡូងមីប្រមាណ៧០% ត្រូវនាំចេញទៅប្រទេសថៃ និងប្រមាណ ៣០% ទៀតគឺសម្រាប់ក្នុងស្រុក។

ក្រៅតែពីការនាំចេញដំឡូងមីស្ងួត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក៏បានស្នើអភិបាលខេត្តក្វាងស៊ី ជំរុញបន្ថែមដល់ក្រុមហ៊ុនចិន បន្តរៀបចំអនុស្សរណៈយោគយល់គ្នាក្នុងការនាំចូលអង្ករ ពោត ស្វាយ ចេក និងផលិតផលសក្តានុពលផ្សេងៗទៀតរបស់កម្ពុជាទៅកាន់តំបន់ស្វយ័តក្វាងស៊ីផងដែរ។

នៅឆ្នាំ២០២១ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងប្រទេសចិនសម្រេចបានកំណើនប្រមាណ ៣៨% បើធៀបនឹងឆ្នាំ ២០២០។ ក្នុងនោះ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងខេត្តក្វាងស៊ី មានប្រមាណជិត១៦០លានដុល្លារ កើនឡើងជិត ៦៤%៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២។*

## ក្រុមហ៊ុននៅកម្ពុជាដំបូងគេមួយនាំចេញទំនិញទៅកាន់ទីផ្សារចិន ក្រោមកិច្ចព្រមព្រៀង RCEP




*ដោយ ខេមបូណូមីស*

នៅទីបំផុតកម្ពុជាមានការនាំចេញទំនិញក្រោមកិច្ចព្រៀមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់(RCEP)ជាលើកដំបូង។ ការនាំចេញនេះ ធ្វើឡើងតាមរយៈក្រុមហ៊ុនWincrown (Cambodia) Industrial ដើម្បីនាំចេញស្បែកជើងបុរសនារីចំនួន៦ប្រភេទស្មើនឹងប្រមាណ ៥ ៦០០គូទៅកាន់ទីផ្សារចិន ដែលក្រុមហ៊ុនទើបទទួលបានវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ(CO) ពីក្រសួងពាណិជ្ជកម្មកាលពីពេលថ្មីៗ កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។ Wincrown បានក្លាយជាក្រុមហ៊ុនដំបូងគេ ដែលបាននាំចេញទំនិញទៅកាន់ទីផ្សារអន្តរជាតិក្រោមកិច្ចព្រមព្រៀង RCEP បន្ទាប់ពីកិច្ចព្រមព្រៀងនេះបានចូលជាធរមានជិតពីរខែកន្លងមកនេះ។

ក្រសួងពាណិជ្ជកម្ម បានគូសបញ្ជាក់ថា ដើម្បីជួយសម្រួលដល់ការនាំចេញទំនិញពីកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ក្រុមហ៊ុននាំចេញទាំងអស់អាចនាំចេញទំនិញមុន ហើយមកស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមក្រោយក៏បានដែរ។ ជាក់ស្តែងក្រុមហ៊ុនខាងលើ បាននាំចេញទំនិញទៅចិនតាំងពីថ្ងៃទី៣ ខែកុម្ភៈ មកម្ល៉េះ តែក្រុមហ៊ុននេះទើបមកដាក់ពាក្យស្នើសុំ និងក្រសួងបានចេញ CO ជូននៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។

ដើម្បីជួយជំរុញកំណើននាំចេញក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិនឱ្យកាន់តែល្អប្រសើរ ក្រសួងពាណិជ្ជកម្ម នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយជូនដល់ក្រុមហ៊ុនផលិត និងនាំចេញ ក្នុងគោលបំណងផ្សព្វផ្សាយឱ្យក្រុមហ៊ុនទាំងនោះយល់ដឹងពីអត្ថប្រយោជន៍ និងនីតិវិធីផ្សេងៗក្នុងការស្នើសុំនាំចេញទំនិញក្រោមកិច្ចព្រមព្រៀងទាំងពីរ។ កិច្ចព្រមព្រៀងទាំងពីរនេះ មានភាពល្អប្រសើរជាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-អាស៊ាន និងអាស៊ានបូក ដែលកម្ពុជាបានអនុវត្តកន្លងមក។ ជាក់ស្តែងនៅពេញ១ខែដើមឆ្នាំ២០២២ ការនាំចេញរបស់កម្ពុជាទៅទីផ្សារគោលដៅទាំងនេះ សម្រេចបានជិត៧រយលានដុល្លារអាមេរិក កើនឡើង២៣% ដែលមានទំហំទឹកប្រាក់ជិត១៣០លានដុល្លារអាមេរិក បើធៀបនឹងខែមករា កាលពីឆ្នាំមុន។

ក្នុងនោះនាំចេញទៅទីផ្សារអាស៊ានសម្រេចបានជិត៥រយលានដុល្លារកើនឡើង៣៩%, ទីផ្សារអូស្ត្រាលីសម្រេចបានជិត១៣លានដុល្លារកើនឡើង២៧%, ចិនសម្រេចបានជិត៨២លានដុល្លារថយចុះ១២%, ជប៉ុនសម្រេចបានជាតិ៨៦លានដុល្លារថយចុះ៣%, កូរ៉េខាងត្បូងសម្រេចបានជាង១៩លានដុល្លារកើនឡើង១៧% និងនូវែលសេឡង់សម្រេចបានជាង១លានដុល្លារកើនឡើង៥១%។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ការប្រៀបធៀបស្ថិតិនាំចូលទំនិញមកកម្ពុជា ក្នុងខែតុលា ឆ្នាំ២០២១ *(ឯកតា៖ ប៊ីលានរៀល)*

| ល.រ | ស្ថិតិនាំចូលទំនិញ | ២០២១ | | កំណើន |
|---|---|---|---|---|
| | | កញ្ញា | តុលា | (%) |
| 1 | ថ្នាំពេទ្យ | 368.4 | 263.4 | -28.5% |
| 2 | បារី | 41.5 | 52.1 | 25.5% |
| 3 | ម្ហូបអាហារ និងភេសជ្ជៈ | 272 | 260.6 | -4.2% |
| 4 | សម្ភារៈសំណង់ | 551.9 | 419.1 | -24.1% |
| 5 | ស៊ីម៉ង់ត៍ | 11.5 | 6.3 | -45.2% |
| 6 | ដែក | 91.2 | 76.3 | -16.3% |
| 7 | ទូរស័ព្ទ | 12.7 | 13.0 | 2.4% |
| 8 | ទូរទស្សន៍ | 5.4 | 1.5 | -72.2% |
| 9 | ឧបករណ៍អេឡិចត្រូនិចផ្សេងទៀត | 283.1 | 203.7 | -28.0% |
| 10 | សម្លៀកបំពាក់ | 198.3 | 192.8 | -2.8% |
| 11 | ក្រណាត់ | 1678.2 | 1782.1 | 6.2% |
| 12 | រថយន្ត | 486.0 | 470.1 | -3.3% |
| 13 | ម៉ាស៊ីនត្រជាក់ ទូទឹកកក ទូក្លាសេ្ស | 26.2 | 16.9 | -35.5% |
| 14 | មាស | 981.3 | 2250.4 | 129.3% |
| 15 | ប្រេងឥន្ធនៈ | 665.3 | 772.2 | 16.1% |
| 16 | ដី | 109.9 | 120.9 | 10.0% |
| 17 | ផ្សេងៗ | 3263.9 | 3038.3 | -6.9% |
| | សរុបរួម | 9046.8 | 9940 | 9.9% |

*ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

តារាងទី១៖ តារាងខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបការនាំចូលទំនិញមកប្រទេសកម្ពុជា ក្នុងខែតុលា ឆ្នាំ២០២១ ដែលមានកំណើនប្រហែល ១០% បើធៀបនឹងខែមុន។ បើយោងតាមព័ត៌មានស្ថិតិសេដ្ឋកិច្ច និងរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដែលបានចេញផ្សាយ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។

ទំនិញដែលនាំចូលទាំងអស់ខាងលើនេះ រួមមាន ៖ ថ្នាំពេទ្យ បារី ម្ហូបអាហារនិងភេសជ្ជៈ សម្ភារៈសំណង់ ស៊ីម៉ង់ត៍ ដែក ទូរស័ព្ទ ទូរទស្សន៍ ឧបករណ៍អេឡិចត្រូនិចផ្សេងទៀត សម្លៀកបំពាក់ ក្រណាត់ រថយន្ត ម៉ាស៊ីនត្រជាក់ ទូទឹកកក ទូក្លាសេ្ស មាស ប្រេងឥន្ធនៈ ដី និងផ្សេងៗ។ ការនាំចូលទំនិញក្នុងខែតុលា នៃឆ្នាំ២០២១នេះ មានការកើនឡើងយ៉ាងខ្លាំង១២៩% លើទំនិញមាស។ បារី ប្រេងឥន្ធនៈ ដី ក្រណាត់ និងទូរស័ព្ទមានកំណើន ២៦%, ១៦%, ១០%, ២% រៀងគ្នា បើធៀបនឹងខែមុន។

ទូរទស្សន៍ ស៊ីម៉ង់ត៍ ម៉ាស៊ីនត្រជាក់ ទូទឹកកក ទូក្លាសេ្ស ថ្នាំពេទ្យ ឧបករណ៍អេឡិចត្រូនិចផ្សេងទៀត សំភារៈសំណង់ ផ្សេងៗ ម្ហូបអាហារនិងភេសជ្ជៈ និង (រថយន្ត, សម្លៀកបំពាក់ស្មើគ្នា)មានកំណើនថយ ៧២%, ៤៥%, ៣៥%, ២៩%, ២៨%, ២៤%, ៧%, ៤%, ៣% រៀងគ្នា បើធៀបនឹងខែមុន៕ *ដោយ ឈន ហាំ*

*ប្រភព៖ធនាគារជាតិ នៃកម្ពុជា ចុះនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២*

### តារាងទី២៖ ការប្រៀបធៀបស្ថិតិនាំចេញទំនិញរបស់កម្ពុជា ក្នុងខែតុលា ឆ្នាំ២០២១ (ឯកតា៖ ប៊ីលានរៀល)

| ល.រ | ស្ថិតិនាំចេញទំនិញ | ២០២១ | | កំណើន |
|---|---|---|---|---|
| | | កញ្ញា | តុលា | (%) |
| 1 | សម្លៀកបំពាក់ | 3291.2 | 2886.7 | -12.3% |
| 2 | ស្បែកជើង | 426.7 | 469.1 | 9.9% |
| 3 | ផលិតផលវាយនភណ្ឌផ្សេងទៀត | 769.2 | 707.3 | -8.0% |
| 4 | គ្រឿងបំណែកអេឡិចត្រូនិច | 551.7 | 346.8 | -37.1% |
| 5 | គ្រឿងបន្លាស់រថយន្ត និងកង់ | 41.0 | 31.8 | -22.4% |
| 6 | កង់ | 223.6 | 170.3 | -23.8% |
| 7 | ផលិតផលអំពីឈើ | 237.7 | 227.7 | -4.2% |
| 8 | អង្ករ | 144.2 | 166.9 | 15.7% |
| 9 | កៅស៊ូ | 157.4 | 166.1 | 5.5% |
| 10 | ផលិតផលនេសាទ និងកសិកម្មផ្សេងទៀត | 72.2 | 53.3 | -26.2% |
| 11 | ផ្សេងៗ | 980.9 | 915.0 | -6.7% |
| | សរុបរួម | 6895.8 | 6141.0 | -10.9% |

*ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

តារាងទី២៖ តារាងខាងលើនេះបានបង្ហាញថា ពីការប្រៀបធៀបការនាំចេញទំនិញរបស់កម្ពុជា ក្នុងខែតុលា

ឆ្នាំ២០២១ មានកំណើនថយ១១% បើធៀបនឹងមុន។ នេះបើយោងតាមព័ត៌មានស្ថិតិសេដ្ឋកិច្ច និងរូបិយវត្ថុ របស់ធនាគារជាតិនៃកម្ពុជា ដែលបានចេញផ្សាយនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។

ទំនិញនាំចេញទាំងអស់ខាងលើនេះ រួមមាន៖ សម្លៀកបំពាក់ ស្បែកជើង ផលិតផលវាយនភណ្ឌផ្សេងទៀត គ្រឿងបំណែកអេឡិចត្រូនិច គ្រឿងបន្លាស់រថយន្តនិងកង់ កង់ ផលិតផលអំពីឈើ អង្ករ កៅស៊ូ ផលិតផលនេសាទ និងកសិកម្មផ្សេងទៀត និងផ្សេងៗ។

ការនាំចេញទំនិញក្នុងខែតុលា ឆ្នាំ២០២១នេះ គឺថយចុះ ៣៧%, ២៦%, ២៤%, ២២%, ១២%, ៧%, ៤% រៀងគ្នា នៃគ្រឿងបំណែកអេឡិចត្រូនិច ផលិតផលនេសាទ និងកសិកម្មផ្សេងទៀត កង់ គ្រឿងបន្លាស់ រថយន្តនិងកង់ សម្លៀកបំពាក់ ផលិតផលវាយនភណ្ឌផ្សេងទៀត ផ្សេងៗ និងផលិផលអំពីឈើ បើធៀបនឹងខែមុន។

កំណើន ១៦%, ១០%, ៦% រៀងគ្នា នៃអង្ករ ស្បែកជើង និងកៅស៊ូ បើធៀបនឹងខែមុន៕ *ដោយ ឈន ហាំ*

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា ចុះនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### តើអាស៊ាន អាចនឹងរងឥទ្ធិពលយ៉ាងណាខ្លះពីសង្គ្រាមរុស្ស៊ីអ៊ុយក្រែន?




*ដោយ ខេមបូណ្ឌមីស(រូបតំណាង)*

សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែននៅឆ្ងាយពីតំបន់អាស៊ានក៏ពិតមែន ក៏ប៉ុន្តែបានជះឥទ្ធិពលគួរឱ្យកត់សម្គាល់មកលើអាស៊ាន ពិសេសវិស័យសេដ្ឋកិច្ច ។ តើសង្គ្រាមនេះ ជះឥទ្ធិពលយ៉ាងណាខ្លះ?

**សេដ្ឋកិច្ច/ពាណិជ្ជកម្ម អាស៊ានអាចខាតច្រើនជាងចំណេញ!**

ទាំងរុស្ស៊ី និងអ៊ុយក្រែនមានទំនាក់ទំនងសេដ្ឋកិច្ចតិចតួចជាមួយអាស៊ាន។ រុស្ស៊ី មានតែជាង ០,៥% នៃទំហំពាណិជ្ជកម្មសរុបកាលពីឆ្នាំ២០២០ ខណៈអ៊ុយក្រែនមានត្រឹម ០,១%។ ទំនាក់ទំនងសេដ្ឋកិច្ច នេះ មានកាន់តែស្តួចស្តើងថែមទៀតក្នុងការវិនិយោគ។ ជាក់ស្តែងប្រទេសរុស្ស៊ីមានត្រឹមតែ ០,០៤៦% នៃការវិនិយោគផ្ទាល់ពីបរទេសទៅក្នុងតំបន់អាស៊ាន រីឯអ៊ុយក្រែនមាន ០,០០៣%។

យ៉ាងណាក៏ដោយ ចំណងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរនឹងអាស៊ាន ក៏មានវិស័យខ្លះ ខ្វះគ្នាមិនបានផងដែរ។ រុស្ស៊ី ជាអ្នកផ្គត់ផ្គង់ជីកសិកម្មធំលំដាប់ទី៣ឱ្យអាស៊ាន បន្ទាប់ពីចិន និង កាណាដា។ ដោយសារតែប្រទេសទាំង១០នៅអាស៊ាន នៅជាប្រទេសមានសេដ្ឋកិច្ចពឹងផ្អែកខ្លាំងលើវិស័យកសិកម្ម ដូច្នេះហើយការប៉ះទង្គិចលើការផ្គត់ផ្គង់ជីកសិកម្ម អាចនឹងជះឥទ្ធិពលមិនល្អដល់កសិផលអាស៊ាន។ ដូចគ្នានេះដែរ វៀតណាមជាអ្នកនាំចេញផលិតផលអេឡិចត្រូនិចជាច្រើនទៅរុស្ស៊ី ក៏ទំនងនឹងរងផលប៉ះពាល់ដែរ។ វៀតណាមបាននាំចេញគ្រឿងចក្រ និងឧបករណ៍អេឡិចត្រូនិចមានតម្លៃសរុប ១ ៥០០លានដុល្លារ រួមទាំងស្មាតហ្វូនផងដែរ ទៅកាន់ប្រទេសរុស្ស៊ីក្នុងឆ្នាំ ២០២២។ ពាណិជ្ជកម្មនេះ អាចនឹងធ្លាក់ចុះ ប្រសិនបើសហរដ្ឋអាមេរិកផ្តើមប្រើប្រាស់ច្បាប់ការពារផលិតផលរបស់ខ្លួននៅក្រៅប្រទេស ដែលចង់ផ្តោតការដាក់សម្ពាធលើរុស្ស៊ី ដែលឈានទៅដល់ការរឹតបន្តឹងការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យារបស់សហរដ្ឋអាមេរិកជាដើម។ គួរជម្រាបថា ក្រុម

ហ៊ុនបច្ចេកវិទ្យារបស់អាមេរិកជាច្រើន កំពុងវិនិយោគនៅក្នុងប្រទេសវៀតណាម។

បញ្ហាសំខាន់មួយទៀត ដែលអាចដាក់សម្ពាធលើតំបន់អាស៊ាន គឺកើតចេញពីទីផ្សារថាមពលពិភពលោក។ តម្លៃប្រេង និងឧស្ម័នបានកើនឡើងរួចទៅហើយ សូម្បីតែនៅមុនពេលប្រតិបត្តិការយោធារបស់រុស្ស៊ីបានចាប់ផ្តើម។ បន្ថែមពីលើនេះ សព្វាវុធ គឺជាការរួមចំណែកដ៏លេចធ្លោជាងគេមួយរបស់រុស្ស៊ីទៅដល់អាស៊ាន។ ទីក្រុងមូស្គូ គឺជាអ្នកផ្គត់ផ្គង់អាវុធដ៏ធំបំផុតដល់តំបន់អាស៊ីអាគ្នេយ៍ចន្លោះពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០១៨ ដែលមានចំនួន ២៦% នៃចំនួនសរុបដែលតំបន់នេះទទួលបាន។

ប៉ុន្តែថ្មីៗនេះ កិច្ចព្រមព្រៀងសព្វាវុធរបស់រុស្ស៊ី បានទទួលផលអាក្រក់មួយផ្នែក ដោយសារតែការដាក់ទណ្ឌកម្មរបស់សហរដ្ឋអាមេរិក ទៅលើប្រទេសដែលទិញសព្វាវុធពីទីក្រុងមូស្គូ។ ជាឧទាហរណ៍ស្រាប់ ប្រទេសឥណ្ឌូណេស៊ី បានលុបចោលកិច្ចព្រមព្រៀងឆ្នាំ ២០១៨ របស់ខ្លួនដើម្បីទិញយន្តហោះចម្បាំង Su-35 របស់រុស្ស៊ី ដោយទីក្រុងហ្សាកាតាបានងាកមកចុះហត្ថលេខាលើកិច្ចព្រមព្រៀង ទិញយន្តហោះចម្បាំង Rafale របស់បារាំងកាលពីខែកុម្ភៈជំនួសវិញ។

ភាពខុសគ្នានៃទំនាក់ទំនងសេដ្ឋកិច្ច និងនយោបាយរបស់សមាជិកអាស៊ានខ្លះជាមួយរុស្ស៊ី អាចបណ្តាលឱ្យមានការខ្វែងគំនិតគ្នានៅក្នុងអាស៊ានជុំវិញប្រតិកម្មរបស់យោធារុស្ស៊ីទៅលើអ៊ុយក្រែន។ សិង្ហបុរីចេញមុខមុនគេ ដោយបានថ្លែងការណ៍ថ្កោលទោសប្រតិបត្តិការយោធារបស់រុស្ស៊ីនៅថ្ងៃដំបូងនៃវាយប្រហារតែម្តង។ ឥណ្ឌូនេស៊ីបានអំពាវនាវ ឱ្យបញ្ឈប់សង្គ្រាមជាបន្ទាន់។ ប៉ុន្តែម៉ាឡេស៊ី និង ហ្វីលីពីន បានត្រឹមតែបង្ហាញការសោកស្តាយចំពោះអ្វីដែលបានកើតឡើងនៅអ៊ុយក្រែនពេលនេះ។ ចំពោះរបបយោធាមីយ៉ាន់ម៉ា បានហៅការឈ្លានពានអ៊ុយក្រែនដោយរុស្ស៊ីថាជារឿងត្រឹមត្រូវ និងសមហេតុផល។ រដ្ឋមន្ត្រីការបរទេសអាស៊ាន នៅថ្ងៃទី ២៧ ខែកុម្ភៈនេះ បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដោយបានអំពាវនាវឱ្យភាគីក្នុងជម្លោះរុស្ស៊ី-អ៊ុយក្រែន ប្រឹងប្រែងស្វែងរកកិច្ចសន្ទនាឱ្យអស់ពីសមត្ថភាព ដើម្បីទប់ស្កាត់ជម្លោះកុំឱ្យវិវត្តន៍កាន់តែធ្ងន់ធ្ងរ ស្វែងរកដំណោះស្រាយដោយសន្តិវិធីស្របតាមច្បាប់អន្តរជាតិ គោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅតំបន់អាស៊ីអាគ្នេយ៍៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។*

## ថៃបារម្ភថាសង្គ្រាមនៅអ៊ុយក្រែនអាចនឹងជះឥទ្ធិពលអាក្រក់ដល់វិស័យទេសចរណ៍



*ដោយ ខេមបូណ្ឌមីស*

ប្រតិបត្តិករទេសចរណ៍នៅក្នុងប្រទេសថៃ កំពុងតាមដានស្ថានភាពសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែនយ៉ាងយកចិត្តទុកដាក់ ព្រោះជម្លោះនេះបង្កហានិភ័យដល់ការទទួលទេសចរអន្តរជាតិ។ បន្ទាប់ពីប្រាក់រូប (Ruble) របស់រុស្ស៊ីបានធ្លាក់ចុះ ៨% ដោយសារតែទណ្ឌកម្មដែលបានដាក់លើប្រទេសរុស្ស៊ីនេះ អាចបណ្តាលឱ្យកម្លាំងទិញចុះខ្សោយ និងប៉ះពាល់ដល់ការសម្រេចចិត្តក្នុងការធ្វើដំណើររបស់ទេសចរ។ ប្រសិនបើប្រាក់រូបរបស់រុស្ស៊ីធ្លាក់ចុះដល់កម្រិតដូចក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុរុស្ស៊ីឆ្នាំ ២០១៤ នោះទេសចររុស្ស៊ី អាចនឹងផ្អាកផែនការធ្វើ

ដំណើរ ព្រោះដើម្បីសន្សំប្រាក់។ ប្រសិនបើជម្លោះនេះទៅជាសង្គ្រាមរវាងរុស្ស៊ី និងអង្គការណាតូ នោះវារឹតតែជះឥទ្ធិពលកាន់តែខ្លាំងថែមទៀតលើវិស័យទេសចរណ៍ថៃ។

ការដាក់គោលនយោបាយតឹងរ៉ឹងប្រឆាំងនឹងប្រទេសរុស្ស៊ី ធ្វើឱ្យចំណាយលើការធ្វើដំណើរតាមផ្លូវអាកាសកាន់តែកើន ដោយសារតែការកើនឡើងតម្លៃប្រេង និងការហាមឃាត់ជើងហោះហើរទាំងសងខាង។ រុស្ស៊ីទើបតែបានលុបចោលការហាមឃាត់ជើងហោះហើររបស់ខ្លួនទៅកាន់ប្រទេសថៃ។ តែអ្នកជំនាញរំពឹងថា ទីផ្សាររុស្ស៊ី នឹងបន្តជាមួយនឹងផែនការធ្វើដំណើរ ដរាបណាក្រុមហ៊ុនអាកាសចរណ៍នៅតែដំណើរការ។

ភ្ញៀវទេសចរពីរុស្ស៊ី គឺបានធ្វើដំណើរមកប្រទេសថៃច្រើនជាងគេ ក្នុងអំឡុងពេល ២២ ថ្ងៃដំបូងនៃការចាប់ផ្ដើមឡើងវិញនូវគម្រោង Test & Goរបស់ថៃក្នុងខែកុម្ភៈនេះ ហើយក៏មានទេសចរមកពីប្រទេសអាល្លឺម៉ង់ និងប្រទេសបារាំងដែរ៕ *ដោយ ម៉ែន ខែមវៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។*

## បើសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនអូសបន្លាយ ឬបន្តរីករាលដាល នឹងអាចប៉ះពាល់ដល់ការនាំចេញពីកម្ពុជាទៅអឺរ៉ុប




*ដោយ ខេមបូណូមីស(ការនាំចេញទំនិញកម្ពុជានៅកំពង់ផែក្រុងព្រះសីហនុ)*

ក្នុងរយៈពេល១សប្ដាហ៍ក្រោយនៃការផ្ទុះសង្គ្រាមនៅអ៊ុយក្រែន មិនបានធ្វើឱ្យប៉ះពាល់ដល់ការនាំចេញពីកម្ពុជាទៅកាន់ទីផ្សារអឺរ៉ុបនោះទេ។ ពោលគឺការនាំចេញ និងការបញ្ជាទិញផលិតនានាដូចជា សម្លៀកបំពាក់ និងវាយនភណ្ឌ និងអង្កររបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុបនៅតែមានជាហូរហែ។ ចំពោះការដឹកជញ្ជូន និងផ្គត់ផ្គង់ទំនិញរបស់កម្ពុជាទៅកាន់ទីផ្សារប៉ែកអឺរ៉ុបនៅប្រព្រឹត្តទៅជាធម្មតា ពុំមានការរាំងស្ទះណាមួយពីនោះទេ។ អ្វីដែលជាបញ្ហាចោទសម្រាប់ការនាំចេញអង្ករកម្ពុជានោះគឺ កង្វះទូកុងតឺន័រ និងថ្លៃដឹកជញ្ជូនឡើងថ្លៃ។

អ្នកស្រាវជ្រាវសេដ្ឋកិច្ច និងជាប្រធានមជ្ឈមណ្ឌលសិក្សាចិននៃរាជបណ្ឌិតសភាកម្ពុជា កត់សម្គាល់ឃើញថា វិបត្តិនៅអ៊ុយក្រែនក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះមិនបានធ្វើឱ្យប៉ះពាល់ដល់ចរន្តនាំចេញ និងផ្គត់ផ្គង់ទំនិញពីកម្ពុជាទៅទីផ្សារអឺរ៉ុបនោះទេ។ ប្រសិនសង្គ្រាមនេះ អូសបន្លាយ វានឹងមានការរំខានដល់ការផ្គត់ផ្គង់ប្រេងឆៅ និងឧស្ម័នពីរុស្ស៊ី ឬក៏រុស្ស៊ី អាចនឹងសងសឹក ដោយការបិទលំហូរឧស្ម័ន ទៅកាន់សហភាពអឺរ៉ុបវិញ បន្ទាប់ពីរុស្ស៊ីបានរងនូវទណ្ឌកម្មជាច្រើន។ ប្រការនេះ អាចនឹងប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចអឺរ៉ុប ដែលជាទីផ្សារធំរបស់កម្ពុជា៕ *ដោយ ម៉ែន ខែមវៈ*

*ប្រភព៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។*

## តើការហោះហើរពីតំបន់អឺរ៉ុបមកកម្ពុជា អាចរងឥទ្ធិពលពីវិបត្តិសង្គ្រាមនៅអ៊ុយក្រែនទេ ?




*(រូបតំណាង៖ រូបភាពហ្វេសប៊ុក អាកាសយានដ្ឋាន)*

បញ្ហាផ្ទុះឡើងនូវសង្គ្រាមនៃប្រទេសមហាអំណាចរុស្ស៊ី និងអ៊ុយក្រែន កំពុងបង្កជាក្ដីបារម្ភចំពោះវិស័យអាកាសចរណ៍ ដ្បិតថា ប្រទេសអឺរ៉ុប និងរុស្ស៊ីបានបិទដែនអាកាសរវាងគ្នា មិនឱ្យយន្តហោះ ហោះហើរទៅមកទេ។

សម្រាប់កម្ពុជានាពេលកន្លងមក ក៏មានប្រជាជនមកពីតំបន់អឺរ៉ុបមួយចំនួនដែរ ដែលបានធ្វើដំណើរចូលមកកម្ពុជា ទាំងជាភ្ញៀវទេសចរ និងអ្នកវិនិយោគ។ តើសង្គ្រាមនេះ អាចជះឥទ្ធិពលអវិជ្ជមានដល់ការហោះហើរពីតំបន់អឺរ៉ុបមកកាន់កម្ពុជាដែរ ឬយ៉ាងណា?

ក្រុមអ្នកជំនាញក្នុងវិស័យអាកាសចរណ៍ សុទ្ធតែអះអាងថា សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន មិនបានជះឥទ្ធិពលដល់ការហោះហើរពីអឺរ៉ុបមកកម្ពុជានោះទេ។ រហូតមកដល់ពេលនេះ មិនទាន់មានការផ្អាកជើងហោះហើរពីតំបន់អឺរ៉ុបនោះទេ។

អ្នកនាំពាក្យអាកាសចរណ៍ស៊ីវិល បានលើកឡើងថា បច្ចុប្បន្ន បណ្តាប្រទេសជាច្រើនលើពិភពលោកបានបិទជើងហោះហើរជាមួយប្រទេសរុស្ស៊ី យ៉ាងណាក៏ដោយ សម្រាប់កម្ពុជា មិនមានផលប៉ះពាល់អ្វីនោះទេ ព្រោះកន្លងមកអ្នកដំណើរដែលចូលមកកម្ពុជា ភាគច្រើនគឺជាជនជាតិចិន វៀតណាម និងថៃ ជាដើម ខណៈអ្នកដំណើរមកពីតំបន់អឺរ៉ុបមានតិចតួចបំផុត។

បច្ចុប្បន្ន ក្រុមហ៊ុនអាកាសចរណ៍ពីតំបន់អឺរ៉ុប មានតែពីរប៉ុណ្ណោះ។ ទាក់ទិននឹងវិស័យអាកាសចរណ៍កម្ពុជា ដ្បិតកម្ពុជាជួបបញ្ហាមេរោគបំប្លែងថ្មី អូមីក្រុង ប៉ុន្តែវាមិនបានធ្វើឱ្យកម្ពុជា ផ្អាកជើងហោះហើរជាមួយប្រទេសដទៃម្តងទៀតនោះទេ ថែមទាំងមានក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិថ្មីៗ បានបង្ហាញពីបំណងបើកជើងហោះហើរជាមួយកម្ពុជាបន្ថែមផងដែរ។ ជាក់ស្តែង នាខែមីនា នេះ ក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិចំនួន២ នឹងចាប់ផ្តើមបើកជើងហោះហើរពីប្រទេសថៃ មកកាន់ប្រទេសកម្ពុជា។

ចាប់តាំងពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ប្រកាសបើកប្រទេសឡើងវិញ ចំនួននៃជើងហោះហើរបានកើនឡើងពី ៣០ជើង ដល់៥០ជើង ក្នុងមួយសប្តាហ៍ ហើយសព្វថ្ងៃ មានក្រុមហ៊ុនអាកាសចរណ៍ចំនួន ១៨ក្រុមហ៊ុន បាននិងកំពុងដំណើរការអាជីវកម្មរបស់ខ្លួន៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។*

## ធនាគារជាតិថៃ ព្រមានអំពីអតិផរណាខ្ពស់ជាងមុន *ប្រភព*




Protesters rally against the Russia-Ukraine conflict in front of the Russian Embassy in Bangkok on Feb 25. Pornprom Satrabhaya

*៖ Bangkok Post ២០២១*

ការវាយប្រហាររបស់រុស្ស៊ីលើអ៊ុយក្រែន នឹងជំរុញឱ្យតម្លៃថាមពលសកលកើនឡើងដោយសារប្រទេសទាំងពីរជាអ្នកផលិតទំនិញសំខាន់ៗ និងឥន្ធនៈហ្វូស៊ីលដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ប្រេងសកល នេះបើយោងតាមលោកស្រី Chayawadee Chai-Anant អគ្គនាយកជាន់ខ្ពស់នៃធនាគារជាតិថៃ ខណៈ ជាមួយនឹងសេណារីយ៉ូនេះ សេដ្ឋកិច្ចថៃអាចប្រឈមនឹងអត្រាអតិផរណាខ្ពស់ជាងមុន។

ប្រទេសថៃនឹងប្រឈមមុខនឹងការកើនឡើងអតិផរណានៅក្នុងឆមាសទី១ នៃឆ្នាំ២០២២ យោងតាមការព្យាករណ៍ពីមុនរបស់ធនាគារជាតិថៃ។ អត្រាអតិផរណាត្រូវបានកំណត់គោលដៅក្នុងកម្រិត ១%-៣% នៅឆ្នាំ២០២២ ដោយសារការកើនឡើងនៃតម្លៃសកលដែលបណ្តាលមកពីផលប៉ះពាល់នៃជំងឺកូវីដ-១៩។

លោកស្រី Chayawadee បានបញ្ជាក់ថា ធនាគារជាតិថៃ នឹងតាមដានបន្ថែមទៀតនូវអត្រាអតិផរណារបស់ប្រទេស ស្របពេលមានភាពមិនច្បាស់លាស់កាន់តែ

ខ្លាំង ហើយធនាគារនឹងពិនិត្យមើលការព្យាករណ៍អត្រាអតិផរណារបស់ខ្លួនម្តងទៀត។

ក្រៅពីតម្លៃប្រេងខ្ពស់ និងអតិផរណានៅទូទាំងពិភពលោក ជម្លោះរវាងរុស្ស៊ី-អ៊ុយក្រែន ក៏អាចបង្កើនការប្រែប្រួលទីផ្សារហិរញ្ញវត្ថុពិភពលោក ខណៈពេលដែលកាត់បន្ថយការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។

ការដាក់ទណ្ឌកម្មរបស់លោកខាងលិចលើប្រទេសរុស្ស៊ី រួមទាំងការកាត់ផ្តាច់ធនាគារមួយចំនួនរបស់រុស្ស៊ីចេញពីប្រព័ន្ធទូទាត់អន្តរធនាគារ SWIFT មានន័យថា ធនាគារជាតិថៃ ចាំបាច់ត្រូវតាមដាននូវផលប៉ះពាល់ធ្ងន់ធ្ងរ រួមទាំងប្រសិនបើធនាគាររុស្ស៊ីបន្ថែមទៀតនឹងត្រូវកាត់ផ្តាច់។ ទោះជាយ៉ាងណា ការកាត់ផ្តាច់ធនាគាររុស្ស៊ីពីប្រព័ន្ធទូទាត់ SWIFT នឹងជះឥទ្ធិពលខ្លាំងដល់ប្រទេសរុស្ស៊ី។

លោកស្រី Chayawadee បានបន្ថែមថា ធនាគារថៃនានាអាចគ្រប់គ្រង និងជួយអតិថិជនដែលនាំចេញ និងនាំចូលពីប្រទេសរុស្ស៊ីទាក់ទងនឹងការទូទាត់ ប៉ុន្តែធនាគារជាតិថៃនឹងតាមដានស្ថានការណ៍យ៉ាងដិតដល់។

សូមបញ្ជាក់ដែរថា ទោះបីជាសេដ្ឋកិច្ចថៃបានធ្លាក់ចុះក្នុងខែមករា ឆ្នាំ២០២២ ធៀបនឹងខែធ្នូ ឆ្នាំ២០២១ ក្តី ប៉ុន្តែកំណើនសេដ្ឋកិច្ចនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២១ គឺល្អប្រសើរជាងការរំពឹងទុក ហើយនឹងក្លាយជាប្រភពដ៏សំខាន់នៃសន្ទុះដែលបន្តជួយដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចថៃនៅឆ្នាំ២០២២ នេះ។ *ដោយ ស៊ិន សុភាព៍*

*ប្រភព៖ Bangkok Post ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២*

## ទិន្នផលរោងចក្ររបស់ជប៉ុន រងការធ្លាក់ចុះដោយសារការកាត់បន្ថយផលិតកម្មរបស់ក្រុមហ៊ុនផលិតរថយន្ត ខណៈវិបត្តិនៅប្រទេសអ៊ុយក្រែនបន្ថែមហានិភ័យ



*ប្រភព៖ CNA ២០២១, រូបភាព៖ REUTERS/Issei Kato*

យោងតាមទិន្នន័យចេញផ្សាយរបស់ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ជប៉ុនបានបង្ហាញថា ទិន្នផលរោងចក្រនៅប្រទេសជប៉ុនបានធ្លាក់ចុះ -១,៣% ក្នុងខែមករា ឆ្នាំ២០២២ ពោលគឺធ្លាក់ចុះខ្លាំងជាងការព្យាករណ៍ដែលមានចំនួន -០,៧% និងជាការធ្លាក់ចុះ ២ខែជាប់គ្នា បន្ទាប់ពីធ្លាក់ចុះ -១,០% ក្នុងខែធ្នូ ឆ្នាំ២០២១ ដោយសារការធ្លាក់ចុះនៃការផលិតរថយន្ត ក៏ដូចជាការផលិតដែក ដែកថែប និងផលិតផលមិនមែនលោហៈ។

កត្តាចម្បង គឺបណ្តាលមកពីផលប៉ះពាល់នៃការផ្ទុះឡើងជំងឺកូវីដ-១៩ បំប្លែងថ្មីអូមីក្រុង នៅក្នុងប្រទេស ក៏ដូចជាបញ្ហាកង្វះបន្ទះឈីប និងការរាំងស្ទះសង្វាក់ផ្គត់ផ្គង់សកល។

ទន្ទឹមនឹងនេះ វិបត្តិនៅប្រទេសអ៊ុយក្រែនក៏កំពុងបង្កើនសម្ពាធហានិភ័យនៃការធ្លាក់ចុះសេដ្ឋកិច្ចរបស់ជប៉ុន នេះបើយោងតាមលោក Takeshi Minami ប្រធានសេដ្ឋវិទូនៅវិទ្យាស្ថានស្រាវជ្រាវ Norinchukin។ ខណៈ សង្គ្រាមរវាងអ៊ុយក្រែន និងរុស្ស៊ី កាន់តែយូរ នោះទណ្ឌកម្មកាន់តែខ្លាំងទំនងជានឹងត្រូវដាក់លើរុស្ស៊ី ហើយក៏អាស្រ័យលើថាតើអ្វីៗនឹងទៅឆ្ងាយប៉ុណ្ណាដែរ។

ជាក់ស្តែង ក្រុមហ៊ុនផលិតរថយន្តជប៉ុន រួមមានៈ ក្រុមហ៊ុន Toyota Motor Corp និង Suzuki Motor Corp បានប្រឈមមុខនឹងការកាត់បន្ថយការផលិត បន្ទាប់ពីរងផលប៉ះពាល់ដោយសារការរាំងស្ទះនៃខ្សែសង្វាក់ផ្គត់ផ្គង់សកល និងមើលឃើញនូវសម្ពាធពីការកើនឡើងនូវកំណត់ត្រានៃការឆ្លងជំងឺកូវីដ-១៩ នៅក្នុងប្រទេស។

ការផលិតរថយន្ត និងទោចក្រយានផ្សេងៗទៀត បានធ្លាក់ចុះ ១៧,២% ក្នុងខែមករា ឆ្នាំ២០២២ ពីខែធ្នូ ឆ្នាំ២០២១ ដែលជាការធ្លាក់ចុះលើកដំបូងក្នុងរយៈពេល ៤ខែ និងបានទាញទម្លាក់តួលេខនៃការផលិតធ្លាក់ចុះជិត ២,៧ពិន្ទុភាគរយ។

ជាមួយគ្នានេះ ភាពស្មុគស្មាញពីវិបត្តិនៅអ៊ុយក្រែន បានបណ្តាលឱ្យធ្លាក់ចុះយ៉ាងខ្លាំងដល់ទិន្នផលផលិតរបស់ជប៉ុន និងសេដ្ឋកិច្ចទាំងមូល ខណៈ ទិន្នផលផលិតគួរតែគ្រប់គ្រងឱ្យបាន ប្រសិនបើជម្លោះនេះបង្កឱ្យមានការខ្វះខាតទំនិញ និងថាមពលសកល៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ Channel News Asia ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២*

## ពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្តាលខែចុងក្រោយនៃខែធ្នូ ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់ប្រទេសវៀតណាម មានចំនួន ១៨,៦៨ ពាន់លានដុល្លារ ខណៈការនាំចូលមានចំនួន ១៦,០៨ ពាន់លានដុល្លារ។ ដូច្នេះ ប្រទេសវៀតណាមមានអតិរេកពាណិជ្ជកម្មចំនួន ២,៦០ ពាន់លានដុល្លារ សម្រាប់ពាក់កណ្តាលខែចុងក្រោយ នៃខែធ្នូ ឆ្នាំ២០២១ ហើយមានកំណើន ១១% បើធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែធ្នូ ឆ្នាំ២០២១។

បើធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែធ្នូ ឆ្នាំ២០២១ ការនាំចេញរបស់វៀតណាមបានកើនឡើង ១៨,៤% ស្មើនឹង ២,៩ ពាន់លានដុល្លារ។ ការកើនឡើងនៃនាំចេញរួមចំណែកដោយម៉ាស៊ីន ឧបករណ៍ និងគ្រឿងបរិក្ខារមាន ២៨,៥% ស្មើនឹង ៥៣២ លានដុល្លារ ទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់មាន១៩,៤% ស្មើនឹង ៤៩៧ លានដុល្លារ វាយនភ័ណ្ឌ និងសម្លៀកបំពាក់មាន ២៧,៨% ស្មើនឹង ៤៣៩ លានដុល្លារ និងកុំព្យូទ័រ និងផលិតផលអគ្គិសនីមាន ១១,៤% ស្មើនឹង ២៨៦ លានដុល្លារ។

ដោយឡែក ការនាំចូលមានទំហំ ១៦,០៨ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្តាលខែចុងក្រោយនៃខែធ្នូ ឆ្នាំ២០២១ បានកើន ៣,៥% ធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែធ្នូ ឆ្នាំ២០២១។ ការនាំចូលត្បូងថ្មបានកើន ៨៥,៤% ស្មើនឹង ១៦០ លានដុល្លារ ចំណីសត្វ និងសម្ភារចំណីសត្វបានកើន ៥៧,៩% ស្មើនឹង ៩៧ លានដុល្លារ ម៉ាស៊ីន ឧបករណ៍ និងគ្រឿងបរិក្ខារបានកើន ៤,៧% ស្មើនឹង ៩២ លានដុល្លារ៕

*ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១៨,៦៨ |
| ការនាំចេញ | ១៦,០៨ |
| តុល្យភាពពាណិជ្ជកម្ម | ២,៦០ |

*ប្រភព៖ Vietnam Customs*

## ពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែមករា ឆ្នាំ២០២២ (គិតជាពាន់លានដុល្លារ)

ការនាំចេញទំនិញសរុបរបស់ប្រទេសឥណ្ឌូនេស៊ីមានទំហំ ១៩,១៦ ពាន់លានដុល្លារ នៅក្នុងខែមករា ឆ្នាំ២០២២ ពោលគឺ ថយចុះ ១៤,២៩% ធៀបទៅនឹងខែធ្នូ ឆ្នាំ២០២១ ប៉ុន្តែបើធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន ការនាំចេញបានកើនឡើង ២៥,៣១%។ ក្នុងនោះ ការនាំចេញផលិតផលមិនមែនប្រេង និងឧស្ម័នមានទំហំ ១៨,២៦ ពាន់លានដុល្លារ នៅក្នុងខែមករា ឆ្នាំ២០២២ បានថយចុះ ១៤,១២% ធៀបទៅនឹងខែធ្នូ

ឆ្នាំ២០២១ ប៉ុន្តែបានកើនឡើង ២៦,៧៤% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការនាំចេញផលិតផលមិនមែនប្រេង និងឧស្ម័នទៅកាន់ចិនមានចំនួន ៣,៥១ ពាន់លានដុល្លារ អាមេរិកមានចំនួន ២,៥៦ ពាន់លានដុល្លារ និងជប៉ុនចំនួនមាន ១,៥១ ពាន់លានដុល្លារ ស្មើនឹង ៤១,៥៧% សម្រាប់ខែមករា ឆ្នាំ២០២២។ ទន្ទឹមនឹងនេះ ការនាំចេញទៅកាន់បណ្ដាប្រទេសអាស៊ានមានចំនួន ៣,៣៤ ពាន់លានដុល្លារ និងសហភាពអឺរ៉ុបមានចំនួន ១,៧០ ពាន់លានដុល្លារ សម្រាប់ខែមករា ឆ្នាំ២០២២។

ចំណែកឯ ការនាំចូលសរុបរបស់ប្រទេសឥណ្ឌូនេស៊ីនៅក្នុងខែមករា ឆ្នាំ២០២២ មានទំហំ ១៨,២៣ ពាន់លានដុល្លារ ធ្លាក់ចុះ ១៤,៦២% ធៀបទៅនឹងខែធ្នូ ឆ្នាំ២០២១ ប៉ុន្តែបើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនបានកើនឡើង ៣៦,៧៧%។ ការនាំចូលផលិតផលប្រេង និងឧស្ម័ន ថយចុះ ៣៤% និងផលិតផលមិនមែនប្រេង និងឧស្ម័ន ថយចុះ ១០,៩៧% ធៀបទៅនឹងខែធ្នូ ឆ្នាំ២០២១។

ការនាំចូលផលិតផលមិនមែនប្រេង និងឧស្ម័នពីចិនមានចំនួន ៥,៨៥ ពាន់លានដុល្លារ ស្មើនឹង ៣៦,៥៥% ជប៉ុនមានចំនួន ១,៣៩ ពាន់លានដុល្លារ ស្មើនឹង ៨,៦៧% និងថៃមានចំនួន ០,៩៣ពាន់លានដុល្លារ ស្មើនឹង ៥,៨៤% សម្រាប់ខែមករា ឆ្នាំ២០២២។ ស្របពេលដែលការនាំចូលប្រេង និងឧស្ម័នពីបណ្ដាប្រទេសអាស៊ានមានចំនួន ២,៧៥ ពាន់លានដុល្លារ ស្មើនឹង ១៧,១៧% និងពីសហភាពអឺរ៉ុបមានចំនួន ០,៩៤ ពាន់លានដុល្លារ ស្មើនឹង ៥,៨៤% សម្រាប់ខែមករា ឆ្នាំ២០២២។

ជារួម ប្រទេសឥណ្ឌូនេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន ០,៩៣ ពាន់លានដុល្លារ នៅក្នុងខែមករា ឆ្នាំ២០២២៕

*ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១៩,១៦ |
| ការនាំចេញ | ១៨,២៣ |
| តុល្យភាពពាណិជ្ជកម្ម | ០,៩៣ |

*ប្រភព៖ https://www.bps.go.id*

## កិច្ចប្រជុំឧត្ដមមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី១ ពិភាក្សាលើរបៀបវារៈជំរុញកំណើនសេដ្ឋកិច្ចនៅអាស៊ាន



*ដោយ វិទ្យុជាតិកម្ពុជា*

កាលពីថ្ងៃទី២១-២២ និងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ នៅទីស្ដីការក្រសួងពាណិជ្ជកម្ម អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ក្នុងនាមជាប្រធានកិច្ចប្រជុំឧត្ដមមន្ត្រីសេដ្ឋកិច្ចអាស៊ាន (SEOM Chair) ក្នុងឆ្នាំ២០២២ បានអញ្ជើញដឹកនាំកិច្ចប្រជុំឧត្ដមមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី១ សម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៣ (The First Meeting of the ASEAN Senior Economic Officials for the Fifty-Third Meeting of the ASEAN Economic Ministers – SEOM 1/53) តាមប្រព័ន្ធវីដេអូ ។ កិច្ចប្រជុំនេះមានការចូលរួមដោយអគ្គលេខាធិការរងអាស៊ានទទួលបន្ទុកសសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន ឧត្ដមមន្ត្រីសេដ្ឋកិច្ចអាស៊ាននៃប្រទេសសមាជិកអាស៊ានទាំងអស់ និងគ

ណៈប្រតិភូនៃប្រទេសសមាជិកអាស៊ាននីមួយៗ ព្រមទាំងមន្ត្រីលេខាធិការដ្ឋានអាស៊ានផងដែរ។ កិច្ចប្រជុំនេះ បានពិភាក្សាលើរបៀបវារៈសំខាន់ៗមួយចំនួន រួមមាន៖ (១) សមិទ្ធផលអាទិភាពសេដ្ឋកិច្ច (PEDs) របស់កម្ពុជាសម្រាប់ភាពជាប្រធានអាស៊ានឆ្នាំ២០២២, (២) អាទិភាពប្រចាំឆ្នាំ ២០២២ របស់ក្រុមការងារអន្តរវិស័យ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន, (៣) កម្មវិធីការងាររបស់ឧត្តមមន្ត្រីសេដ្ឋ កិច្ចអាស៊ានប្រចាំឆ្នាំ ២០២២, (៤) បច្ចុប្បន្នភាពនៃការអនុវត្តក្របខ័ណ្ឌស្តារឡើងគ្រប់ជ្រុង ជ្រោយអាស៊ាន (ACRF), (៥) ការត្រៀមរៀបចំដើម្បីប្រកាសបើកការចរចាធ្វើឱ្យប្រសើរឡើងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន, (៦) ការពិនិត្យលទ្ធភាពដើម្បីពន្យារសុពលភាពអនុស្សរណៈយោគយល់ស្តីពីការអនុវត្តវិធានការមិនមែនពន្ធគយលើមុខទំនិញចាំបាច់ និងការពង្រីកបញ្ជីទំនិញចាំបាច់, (៧) វឌ្ឍនភាពនិងកិច្ចការបន្ទាប់ ស្ថិតក្រោមទំនាក់ទំនងសេដ្ឋកិច្ចជាមួយនឹងដៃគូអាស៊ាន និងបញ្ហាផ្សេងៗទៀតជាច្រើន ។
ពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការ រៀបចំបញ្ជី PEDs កម្ពុជាបានស្នើ PEDs ចំនួន ២ បន្ថែមទៀតក្រោមវិស័យហិរញ្ញវត្ថុ។ ជាលទ្ធផល កិច្ចប្រជុំបានឯកភាពជាគោលការណ៍ និងស្នើឱ្យសមាជិកអាស៊ានទាំងអស់ផ្តល់មតិយោបល់ចុងក្រោយលើ PEDs ដែលនៅសេសសល់ដើម្បីដាក់ជូនកិច្ចប្រជុំចង្អៀតថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី២៨ ពិនិត្យនិងអនុម័ត នៅថ្ងៃទី១៥-១៧ ខែមីនា ឆ្នាំ ២០២២។
អង្គប្រជុំបានកត់សម្គាល់លើវឌ្ឍនភាពនៃការអនុវត្តគំនិតផ្តួចផ្តើមនានា ដែលស្ថិតនៅក្រោមក្របខ័ណ្ឌស្តារឡើងគ្រប់ជ្រុងជ្រោយអាស៊ាន (ACRF) ជាពិសេសសកម្មភាពទាំងឡាយ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន។ វិបត្តិកូវីដ១៩នៅតែបន្តវិខានដល់សេដ្ឋកិច្ច និងសង្គម ទាំងក្នុងតំបន់និងសាកលលោក ដូច្នេះក្របខ័ណ្ឌACRFនៅតែជាយន្តការស្នូលរបស់អាស៊ានដើម្បីឆ្លើយតបនឹងវិបត្តិនេះ។
ស្របគ្នានោះ ចំពោះការពិនិត្យលទ្ធភាពដើម្បីពន្យារសុពលភាពអនុស្សរណៈយោគយល់ស្តីពីការអនុវត្តវិធានការមិនមែនពន្ធគយលើមុខទំនិញចាំបាច់ និងការពង្រីកបញ្ជីទំនិញចាំបាច់ កិច្ចប្រជុំបានកត់សម្គាល់ថាអនុស្សរណៈយោគយល់នេះ ត្រូវបានពន្យារសុពលភាពបន្ថែមចំនួនពីរឆ្នាំទៀត គឺរហូតដល់ខែវិច្ឆិកាឆ្នាំ ២០២៤ ហើយបច្ចុប្បន្នក្រុមការងារពាក់ព័ន្ធ បានឯកភាពពង្រីកបញ្ជីមុខទំនិញចាំបាច់បន្ថែមទៀត ដោយធ្វើការពិភាក្សាក្នុងស្រុកចំពោះមុខទំនិញដែលនឹងត្រូវដាក់បញ្ចូល។ ចំពោះទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្រទេសដៃគូអាស៊ាន កិច្ចប្រជុំបានពិភាក្សាលើកិច្ចការជាច្រើនដូចជា៖ (១) ការត្រៀមរៀបចំនានាដើម្បីចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា, (២)ការធ្វើឱ្យប្រសើរឡើងនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយដៃគូអាស៊ានមួយចំនួន រួមមាន កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលហ្សេឡង់, កិច្ចព្រម ព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និង (៣) ការរៀបចំសេចក្តីព្រាងនៃសេចក្តីប្រកាសរួមស្តីពីកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងសមាគមពាណិជ្ជកម្មសេរីអឺរ៉ុប ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖information.gov ចេញផ្សាយថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២។*

## អាស៊ាន និងប្រទេសឈីលី ប្តេជ្ញាចិត្តក្នុងការពង្រឹងភាពជាដៃគូអភិវឌ្ឍ



*ដោយ AKP*

អាស៊ាន និងប្រទេសឈីលី បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការដៃគូអភិវឌ្ឍអាស៊ាន-ឈីលី (AC-DPC) លើកទី៣ តាមរយៈសន្និសីទវីដេអូ។ អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះរួមមាន សមាជិកគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំនៅអាស៊ាន បណ្តាមន្ត្រីមកពីស្ថានទូតឈីលីប្រចាំនៅប្រទេសឥណ្ឌូណេស៊ី និងលេខាធិការដ្ឋានអាស៊ាន។ កិច្ចប្រជុំ បានពិនិត្យមើលទៅលើការអនុវត្ត PCA ហើយបានកត់សម្គាល់ថា ក្នុងឆ្នាំដំបូងនៃការអនុវត្តនេះ ខ្សែសកម្មភាពចំនួន១០ ក្នុងចំណោម២៦ (ស្មើនឹង ៣៨ភាគរយ) កំពុងត្រូវបានដោះស្រាយ ឬត្រូវបានដោះស្រាយរួចរាល់។ ភាគីទាំងពីរ បានព្រមព្រៀងគ្នាក្នុងការរិះរកវិធីច្នៃប្រឌិតថ្មីៗ ដើម្បីអនុវត្តសកម្មភាពទាំងនោះ។

ភាគីទាំងពីរ បានអះអាងការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការពង្រឹងភាពជាដៃគូអភិវឌ្ឍ ដោយការអនុវត្តវិស័យសហប្រតិបត្តិការជាក់ស្តែង (PCA) សម្រាប់ភាពជាដៃគូអភិវឌ្ឍអាស៊ាន-ឈីលី ឆ្នាំ២០២១-២០២៥ ដែលត្រូវបានអនុម័តកាលពីឆ្នាំមុន។ ភាគីទាំងពីរ ក៏បានពិភាក្សាគ្នាលើវិស័យអាទិភាពមួយចំនួននៃកិច្ចសហប្រតិបត្តិការ ដូចជា វិស័យពាណិជ្ជកម្ម និងការវិនិយោគ កិច្ចសហប្រតិបត្តិការរ៉ែ ថាមពលកកើតឡើងវិញប្រកបដោយចីរភាព និងរួមទាំងប្រសិទ្ធភាពថាមពល សហគ្រាសខ្នាតតូច និងមធ្យម (MSMEs) ការចូលរួមពីវិស័យឯកជន ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការវិនិយោគក្នុងវិស័យព្រៃឈើ ការរកប្រភពត្រីសាម៉ុងប្រកបដោយចីរភាព និងសេដ្ឋកិច្ចក្នុងរង្វង់ចំណីអាហារពីត្រី និងកិច្ចសហប្រតិបត្តិការក្នុងការកសាងសមត្ថភាពនៅក្នុងវិស័យនៃការអភិវឌ្ឍកិច្ចព្រមព្រៀងឌីជីថល។ *ដោយ ម៉ែនខែមរៈ*

*ប្រភព ៖ AKP ចេញផ្សាយ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០២២។*

## សេដ្ឋកិច្ចសកល

### អតិផរណាគ្រឿងទេសនៅចក្រភពអង់គ្លេសឡើងដល់ ៤,៣% ខណៈជម្លោះនៅអ៊ុយក្រែនបន្ថែមសម្ពាធ



*ប្រភព៖ REUTERS/Neil Hall*

អតិផរណាគ្រឿងទេសរបស់អង់គ្លេស បានឡើងដល់ ៤.៣% នៅក្នុងខែកុម្ភៈ ដោយព្រមានពីការប៉ះពាល់កាន់តែខ្លាំងសម្រាប់អ្នកប្រើប្រាស់ ដែលទំនងជាមកពីសម្ពាធខ្សែសង្វាក់ផ្គត់ផ្គង់ដែលកំពុងបន្ត និងផលប៉ះពាល់សក្តានុពលនៃជម្លោះក្នុងប្រទេសអ៊ុយក្រែន។

ក្រៅពីការចាប់ផ្តើមនៃការរាតត្បាតជំងឺកូវីដ១៩ នៅពេលដែលផ្សារទំនើបរបស់ចក្រភពអង់គ្លេស កាត់បន្ថយកិច្ចព្រមព្រៀងផ្សព្វផ្សាយដើម្បីរក្សាផលិតផល ដែលអាចរកទិញបាននោះ អត្រាអតិផរណានៅខែកុម្ភៈគឺជាអត្រាអតិផរណាដែលលឿនបំផុតដែលបានកត់ត្រាចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៣។ ហើយតម្លៃកំពុងកើនឡើងលឿនបំផុតនៅក្នុងទីផ្សារដូចជាអាហារសម្រន់ សាច់

គោស្រស់ និងអាហារឆ្អា ខណៈដែលធ្លាក់ចុះនៅក្នុងសាច់ក្រៀម ស្រាបៀរ និងគ្រឿងស្រវឹង។

អត្រាអតិផរណាតម្លៃទំនិញប្រើប្រាស់ប្រចាំឆ្នាំរបស់ចក្រភពអង់គ្លេស(CPI) បានកើនឡើងដល់៥.៥% នៅក្នុងខែមករា ដែលជាកម្រិតខ្ពស់បំផុតចាប់តាំងពីខែមីនា ឆ្នាំ១៩៩២។ ធនាគារកណ្តាលអង់គ្លេស រំពឹងថា CPI ទាំងមូលនឹងឈានដល់កម្រិតកំពូលប្រហែល 7.25% នៅក្នុងខែមេសា នៅពេលដែលពន្ធលើថាមពលគ្រួសារដែលបានបានដាក់ចេញកើនឡើងជាង ៥០% ។ ទោះជាយ៉ាងណាក៏ដោយ អ្នកវិភាគមួយចំនួនជឿថា ការធ្លាក់ចុះសេដ្ឋកិច្ចពីការឈ្លានពានរបស់រុស្ស៊ីមកលើអ៊ុយក្រែន អាចបណ្តាលឱ្យមានអតិផរណាលើសពីការព្យាករណ៍នោះ។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២*

## ឱនភាពពាណិជ្ជកម្មទំនិញរបស់សហរដ្ឋអាមេរិកបានឡើងដល់កម្រិតខ្ពស់បំផុត ដែលមើលឃើញថាមានទម្ងន់លើកំណើន GDP នៅត្រីមាសទីមួយ




*ប្រភព៖ REUTERS/Mike Blake*

ឱនភាពពាណិជ្ជកម្មសហរដ្ឋអាមេរិកនៅលើទំនិញ បានកើនឡើងយ៉ាងខ្លាំងដល់កម្រិតខ្ពស់បំផុតនៅក្នុងខែមករា ចំពេលមានការកើនឡើងនៃការនាំចូល ខណៈដែលអាជីវកម្មបន្តបំពេញបន្ថែមនូវទំនិញដែលអស់។ ហើយការកើនឡើងនៃឱនភាពពាណិជ្ជកម្មទំនិញ បានជំរុញឱ្យសេដ្ឋវិទូនៅក្រុមហ៊ុន Goldman Sachs កាត់បន្ថយការប៉ាន់ប្រមាណកំណើនផ.ស.ស របស់ពួកគេសម្រាប់ត្រីមាសទី១ ដោយពិន្ទុភាគរយ០.៥ ដល់អត្រាប្រចាំឆ្នាំ ១.៥% ។

សេដ្ឋកិច្ច បានកើនឡើងក្នុងល្បឿន៧% នៅក្នុងត្រីមាសទី៤ ជាមួយនឹងទំនិញដែលរួមចំណែកដល់ ៤.៩%។ ឱនភាពពាណិជ្ជកម្មទំនិញបានកើនឡើង ៧.១% ដល់កម្រិតខ្ពស់គ្រប់ពេលនៃ ១០៧.៦ប៊ីលានដុល្លារកាលពីខែមុន។ ការនាំចូលទំនិញ កើនឡើង១.៧% នាំមុខដោយអាហារ និងយានជំនិះ។ ហើយក៏មានការកើនឡើងយ៉ាងខ្លាំងផងដែរក្នុងការនាំចូលការផ្គត់ផ្គង់ឧស្សាហកម្ម មូលធន និងទំនិញប្រើប្រាស់។ ទោះជាយ៉ាងណា ការនាំចូលទំនិញផ្សេងទៀតបានធ្លាក់ចុះ ១៥.៣% ។

ជាមួយគ្នានេះ ការនាំចេញបានធ្លាក់ចុះ ១.៨% ដោយថ្លឹងថ្លែងដោយទំនិញប្រើប្រាស់ យានយន្ត អាហារ និងទំនិញផ្សេងៗទៀត។ ប៉ុន្តែការនាំចេញទំនិញ មូលធន និងការផ្គត់ផ្គង់ឧស្សាហកម្មបានកើនឡើង។

ពាណិជ្ជកម្ម បានក្លាយជាការអូសទាញលើផ.ស.ស សម្រាប់រយៈពេលប្រាំមួយត្រីមាសជាប់គ្នា។ អ្នកសេដ្ឋកិច្ចមើលឃើញថាមានផលប៉ះពាល់តិចតួចលើពាណិជ្ជកម្មពីជម្លោះរុស្ស៊ី-អ៊ុយក្រែន ដែលបណ្តាលឱ្យសហរដ្ឋអាមេរិកដាក់ទណ្ឌកម្មពាណិជ្ជកម្មដូចគ្នាលើទីក្រុងម៉ូស្គូ។ យោងតាមទិន្នន័យរបស់រដ្ឋាភិបាល បានឱ្យដឹងថា ប្រទេសរុស្ស៊ីមានត្រឹមតែ ១% នៃការនាំចូល និងប្រហែល ០.៤% នៃការនាំចេញកាលពីឆ្នាំមុន។

ដោយឡែក ភាគហ៊ុនរបស់សហរដ្ឋអាមេរិក បានធ្លាក់ចុះនៅពេលវិនិយោគិនបានវាយតម្លៃពីការធ្លាក់ចុះនៃទណ្ឌកម្មដែលដាក់ដោយបណ្តាប្រទេសលោកខាងលិចលើប្រទេសរុស្ស៊ី។ ប្រាក់ដុល្លារ បានកើនឡើងធៀបនឹងកញ្ចប់រូបិយប័ណ្ណនានា ខណៈដែលទិន្នផលរតនាគារសហរដ្ឋអាមេរិក បានធ្លាក់ចុះ។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២*

## សហរដ្ឋអាមេរិក កាត់ផ្ដាច់ធនាគារកណ្ដាលរុស្ស៊ី ចេញពីការជួញដូរប្រាក់ដុល្លារអាមេរិក



រដ្ឋបាលសហរដ្ឋអាមេរិកបានចាត់វិធានាភ្លាមៗ ដើម្បីហាមឃាត់ការជួញដូរប្រាក់ដុល្លារអាមេរិក ជាមួយធនាគារកណ្ដាលរបស់រុស្ស៊ី និងរារាំងមូលនិធិវិនិយោគផ្ទាល់របស់រុស្ស៊ីទាំងមូល។ វិធានការទាំងនេះ គឺសំដៅរារាំងរុស្ស៊ីពីការទទួលបានមូលនិធិដែលគេស្គាល់ថា «rainy day fund» ដែលទីក្រុងម៉ូស្គូបានរំពឹងថានឹងពឹងផ្អែកលើវាក្នុងអំឡុងពេលការឈ្លានពានអ៊ុយក្រែនជំនួសឱ្យការប្រើប្រាស់ប្រាក់បំរុង ដើម្បីការពារប្រាក់រូប្ល(លុយរុស្ស៊ី)ដែលកំពុងធ្លាក់ចុះ។ រុស្ស៊ីនឹងលែងមានសិទ្ធិចូលប្រើប្រាស់ប្រាក់ដែលខ្លួនមានជាដុល្លារអាមេរិកទៀតហើយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ freshnews ចេញផ្សាយថ្ងសទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។*

## ធនាគារកណ្ដាល៖ រុស្ស៊ីមានប្រព័ន្ធផ្ទៃក្នុងដែលអាចជំនួស SWIFT បាន




*ដោយ ខេមបូណ្ឌមីស(ធនាគារកណ្ដាលនៃប្រទេសរុស្ស៊ី)*

សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងចក្រភពអង់គ្លេសបានឯកភាពគ្នាកាត់ផ្ដាច់ធនាគារធំៗមួយចំនួនរបស់រុស្ស៊ីពីប្រព័ន្ធទូទាត់ប្រាក់សាកលលោក ហៅថា SWIFT ដែលជាប្រព័ន្ធចរាចរណ៍ប្រាក់ទៅមកជាមួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗជាច្រើនទៀត នៅទូទាំងសាកលលោក។

ទេសាភិបាលធនាគារកណ្ដាលរបស់រុស្ស៊ីបាននិយាយថា ប្រទេសរុស្ស៊ីមានប្រព័ន្ធមួយដែលអាចជំនួសប្រព័ន្ធទូទាត់ប្រាក់សាកលលោក SWIFT បានសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរវាងធនាគារនានានៅក្នុងប្រទេសរុស្ស៊ី។ ធនាគារទាំងអស់នៅក្នុងប្រទេសរុស្ស៊ី នឹងបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយមូលនិធិទាំងអស់នៅក្នុងគណនីរបស់ពួកគេត្រូវបានរក្សាការពារ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។*

## ផ្សារទំនើបធំបំផុតទី២ នៅហ្វាំងឡង់ ប្រកាសបញ្ឈប់ការលក់ទំនិញរុស្ស៊ី ជាង៥០មុខ



ផ្សារទំនើបធំបំផុតលំដាប់ទី២ នៅប្រទេសហ្វាំងឡង់ បានបញ្ជាឱ្យដកផលិតផលរុស្ស៊ី ប្រហែលជាង៥០មុខចេញពីក្នុងផ្សារ ដោយសារតែស្ថានការណ៍តានតឹងនៅអ៊ុយក្រែន។ មុខទំនិញដែលដកចេញពីការលក់ មានដូចជា ចំណីអាហារ សម្ភារៈកីឡា សំលៀកបំពាក់ ព្រមទាំងទំនិញប្រើប្រាស់ផ្សេងៗទៀត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។*

## តម្លៃប្រេង និងមាសកើនឡើងជាថ្មីទៀត ក្រោយពេលរុស្ស៊ីប្រកាសប្រុងជើងការអាវុធនុយក្លេអ៊ែរ



*ដោយ ខេមបូណ្ឌមីស(រូបតំណាង)*

តម្លៃប្រេង និងមាសបន្តហក់ឡើងថ្លៃបន្ថែមទៀតនៅចន្ទ ដើមសប្តាហ៍នេះ ខណៈពេលដែលប្រធានាធិបតីរុស្ស៊ីបានប្រកាសប្រុងជើងការក្នុងការប្រើអាវុធនុយក្លេអ៊ែររបស់ខ្លួន នៅគ្រាដែលសង្គ្រាមជាមួយអ៊ុយក្រែនកំពុងឆេះឆួលកាន់តែខ្លាំង។ ជាមួយគ្នានេះ ការដាក់កម្រិតលើការទូទាត់តាមប្រព័ន្ធធនាគារ ក៏បានបង្កើនការភ័យខ្លាចដល់អ្នកវិនិយោគផងដែរថា ការនាំចេញប្រេងពីរុស្ស៊ី ដែលជាប្រទេសផលិតប្រេងធំជាងគេបំផុតទី២ក្នុងពិភពលោកនោះ អាចនឹងត្រូវមានការរំខាន។ តម្លៃប្រេងឆៅនៅទីផ្សារអង់គ្លេស បានឡើងដល់ទៅលើស១០០ដុល្លារអាមេរិកក្នុងមួយបារ៉ែល កើនឡើងជាង៧ដុល្លារទៀត។ តម្លៃប្រេងនៅអាមេរិកវិញ ក៏កើនឡើងជាង៤ដុល្លារ៥០សេនបន្ថែមទៀតដែរ នាំឱ្យប្រេង១បារ៉ែលកើនដល់ជាង៩៦ដុល្លារអាមេរិក។ ការដាក់ទណ្ឌកម្មដោយអាមេរិក និងអឺរ៉ុប ក្នុងការដកធនាគាររុស្ស៊ីចេញប្រព័ន្ធទូទាត់សកល SWIFT គឺបានបង្កក្តីបារម្ភកាន់តែខ្លាំងឡើងថា ការផ្គត់ផ្គង់ប្រេង។

ក្រៅតពីតម្លៃប្រេង មាសបានឡើងថ្លៃខ្ពស់បំផុតមិនធ្លាប់មានក្នុងរយៈពេល១ឆ្នាំកន្លងមកនេះ។ តម្លៃមាសសម្រាប់ទីផ្សារញ៉ូយក បានកើនឡើងដល់ជិត២ពាន់ដុល្លារអាមេរិកក្នុងមួយឱន(៨ជីមាស)។ តម្លៃមាសអាចនឹងកើនឡើងដល់ជាង២ពាន់លានដុល្លារ ក្នុងមួយឱន អាស្រ័យលើភាពតានតឹងនៃវិបត្តិសង្គ្រាមនៅអ៊ុយក្រែន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។*

## ប្រាក់រូប្លរបស់រុស្ស៊ីធ្លាក់ចុះដល់កម្រិតទាបបំផុត ក្រោយរងដាក់ទណ្ឌកម្មថ្មីៗពីលោកខាងលិច




*ដោយ ខេមបូណ្ឌមីស*

រូបិយបណ្ណរបស់រុស្ស៊ីបានធ្លាក់ចុះ ៤០% ធៀបនឹងប្រាក់ដុល្លារនៅដើមសប្តាហ៍នេះ បន្ទាប់ពីសហរដ្ឋអាមេរិក និងបណ្តាប្រទេសអឺរ៉ុបសំខាន់ៗបានបន្តដាក់ទណ្ឌកម្មធ្ងន់ធ្ងរបន្ថែមទៀតមកលើធនាគារកណ្តាលរបស់រុស្ស៊ី និងដកធនាគារធំៗរបស់ប្រទេសនេះចេញពីប្រព័ន្ធទូទាត់សកល ស្វីវ (SWIFT)។ ជាក់ស្តែង កាលពីថ្ងៃសុក្រសប្តាហ៍មុន មានតម្លៃ ៨៣រូប្ល ដូរបាន១ដុល្លារអាមេរិក ប៉ុន្តែថ្ងៃចន្ទសប្តាហ៍ថ្មីនេះ ១១៧រូប្ល ទើបដូរបាន១ដុល្លារអាមេរិក។

ឈ្មួញកណ្តាលជប៉ុន បានឈប់ទទួលយកការបញ្ជាទិញថ្មីសម្រាប់ប្រាក់រូប្លរុស្ស៊ី ហើយក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ដែលប្រតិបត្តិការសេវាកម្មប្តូរប្រាក់បរទេសតាមអ៊ីនធឺណិត ក៏បាននិយាយដែរថា ក្រុមហ៊ុនខ្លួន អាចនឹងត្រូវបង្ខំឱ្យបិទការជួញដូរប្រាក់រូប្លរុស្ស៊ីជាមួយប្រាក់យ៉េនជប៉ុនផងដែរ។

ជាមួយគ្នានេះ ទីផ្សារភាគហ៊ុន និងរូបិយប័ណ្ណអាស៊ីក៏មានភាពប្រែប្រួលដែរ នៅពេលព្រឹកថ្ងៃដើមសប្តាហ៍

នេះ ខណៈវិនិយោគិនក៏បានថ្លឹងថ្លែងពីទណ្ឌកម្មថ្មីៗលើរុស្ស៊ី៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៧ ខែមីនា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសចិនបានពង្រីកយ៉ាងខ្លាំងដល់កម្រិតខ្ពស់បំផុត ក្នុងខែធ្នូ ឆ្នាំ 2021
- សមតុល្យសាច់ប្រាក់រតនាគារនៅក្នុងប្រទេសទួរគីបានកើនឡើង នៅក្នុងខែមករា 2022

ថ្ងៃអង្គារ ទី០៨ ខែមីនា ឆ្នាំ២០២២

- ទុនបំរុងប្តូរប្រាក់បរទេសនៅប្រទេសឥណ្ឌូនេស៊ីបានធ្លាក់ចុះ ក្នុងខែមករា ឆ្នាំ 2022
- សេដ្ឋកិច្ចតំបន់អឺរ៉ូបានកើនឡើង 0.3% នៅត្រីមាសក្នុងរយៈពេល 3 ខែចុងក្រោយនៃឆ្នាំ 2021

ថ្ងៃពុធ ទី០៩ ខែមីនា ឆ្នាំ២០២២

- សេដ្ឋកិច្ចជប៉ុនបានកើនឡើង 1.3% qoq នៅក្នុង Q4 2021 ធៀបនឹងការព្យាករណ៍ទីផ្សារ
- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ក្នុងប្រទេសចិនបានកើនឡើង 0.40% ក្នុងខែមករា ឆ្នាំ 2022 ធៀបនឹងខែមុន

ថ្ងៃព្រហស្បតិ៍ ទី១០ ខែមីនា ឆ្នាំ២០២២

- អត្រានីកម្មភាព នៅក្នុងប្រទេសទួរគីបានធ្លាក់ចុះមកត្រឹម 11.20% ក្នុងខែធ្នូ ពី 11.30% ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- តម្លៃទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិកបានកើនឡើង 0.60% ក្នុងខែមករា ឆ្នាំ 2022

ថ្ងៃសុក្រ ទី១១ ខែមីនា ឆ្នាំ២០២២

- សហរដ្ឋអាមេរិកបានកត់ត្រាអតិរេកថវិកាចំនួន 119 ពាន់លានដុល្លារក្នុងខែមករា ឆ្នាំ 2022
- អត្រាអតិផរណាប្រចាំឆ្នាំនៅក្នុងប្រទេសប្រេស៊ីលបានកើនឡើង ក្នុងខែមករា ឆ្នាំ 2022៕